ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សមិទ្ធផល
# របស់និយ័តករបរធនបាលកិច្ច
# ឆ្នាំ២០២៤










បោះពុម្ព
ឆ្នាំ២០២៥

# សាររបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាបន្ន និងសមធម៌សំដៅលើកកម្ពស់ជីវភាពប្រជាជននិងកាត់បន្ថយភាពក្រីក្រ បាននាំកម្ពុជាឈានចូលរបត់ថ្មីនៃប្រវត្តិសាស្ត្រដោយបានប្រែក្លាយមុខមាត់កម្ពុជាពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងបាននិងកំពុងបន្តចក្ខុវិស័យក្នុងការប្រែក្លាយជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ដែលនេះជាសក្ខីភាពមួយសបញ្ជាក់ឱ្យឃើញពីសមិទ្ធផល និងសក្តានុពលនៃការអភិវឌ្ឍរបស់កម្ពុជា។ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយមុនមានការផ្ទុះឡើងនូវវិបត្តិ ជំងឺកូវីដ-១៩ ជាសកល ប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចនិងវឌ្ឍនភាពសង្គមគួរឱ្យកត់សម្គាល់ដោយមានកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧% ជាមធ្យម។

នៅក្នុងក្របខ័ណ្ឌនៃទស្សនវិស័យ និងផ្អែកតាមកម្មវិធីនយោបាយ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមគ្គុទេសក៍វ័យក្មេងដ៏ឆ្នើម និងពោរពេញដោយសមត្ថភាព ចំណេះដឹង និងថាមពល បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ផ្អែកលើមូលដ្ឋាន **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលមានតួនាទីជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា បានបន្តដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងផែនការសកម្មភាពការងារសំខាន់ៗ ដើម្បីឆ្លើយតបនឹងការវិវត្តការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបរធនបាលកិច្ចនៅកម្ពុជា ព្រមទាំងដើម្បីឱ្យវិស័យបរធនបាលកិច្ចបន្តពង្រឹងតួនាទី និងមានការអភិវឌ្ឍដែលមានលក្ខណៈទំនើប និងមានភាពធន់កាន់តែខ្ពស់ ដើម្បីបន្តបង្កើតនូវគុណប្រយោជន៍សម្រាប់សេដ្ឋកិច្ចជាតិ និងសង្គម មានជាអាទិ៍៖ ១- បង្កើនការវិនិយោគក្នុងស្រុកដែលជាប្រភពនៃការបន្ថែមចំណូលពន្ធជាតិ, ២- ជំរុញការធ្វើពិពិធកម្មដល់វិស័យហិរញ្ញវត្ថុ សម្រាប់ឆ្លើយតបនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុ ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា និង ៣- ចូលរួមក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការទប់ស្កាត់នឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ក្នុងឆ្នាំ២០២៤ នេះ តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាកន្លងមក **ន.ប.ធ.** បន្តសម្រេចបាននូវសមិទ្ធផលសំខាន់ៗច្រើនទៀត មានជាអាទិ៍៖ ការបន្តបង្កើតឱ្យមាននូវបទដ្ឋានគតិយុត្តនានាដើម្បីបន្តសម្រាប់គ្រប់គ្រងវិស័យបរធនបាលកិច្ចប្រកបដោយប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងមានសណ្តាប់ធ្នាប់, ការបន្តពង្រឹង និងអភិវឌ្ឍធនធានមនុស្សរបស់ស្ថាប័ន, ការបន្តផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ និងការចុះបញ្ជីបរធនបាលកិច្ចដល់ប្រតិបត្តិករក្នុងវិស័យបរធនបាលកិច្ច, ការបន្តពង្រឹង និងការអនុវត្តច្បាប់, ការបន្តការចុះធ្វើអធិការកិច្ចក្នុងវិស័យបរធនបាលកិច្ច, ការបន្តសិក្សាស្រាវជ្រាវដំណើរការអភិវឌ្ឍន៍ និងនវានុវត្តន៍វិស័យបរធនបាលកិច្ច, ការបន្តរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពីវិស័យបរធនបាលកិច្ចដល់សាធារណជន និងភាគីពាក់ព័ន្ធនានា និងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅតំបន់។

របាយការណ៍សមិទ្ធផល ដែលឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា កំពុងកាន់ក្នុងដៃនេះ គឺជារបាយការណ៍ដែលបង្ហាញនូវសមិទ្ធផលសំខាន់ៗរបស់ **ន.ប.ធ.** ដែលសម្រេចបានក្នុងឆ្នាំ២០២៤។ សមិទ្ធផលដែលសម្រេចបាននេះ គឺអាស្រ័យដោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និយ័តករ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែងប្រកបដោយគំនិតច្នៃប្រឌិតរបស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និង **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំបច្ចេកទេសនៃ **អ.ស.ហ.** ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុអភិវឌ្ឍន៍វិស័យ

បរធនបាលកិច្ច។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រតិបត្តិករ ក្រុមហ៊ុនបរធនបាល អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ចទាំងអស់ដែលបានផ្តល់កិច្ចសហប្រតិបត្តិការខ្ពស់ក្នុងការចូលរួមការអភិវឌ្ឍវិស័យបរធនបាលកិច្ចឱ្យបានរីកចម្រើនលូតលាស់រហូតមកដល់ពេលនេះ។ ជាចុងក្រោយ ខ្ញុំមានសេចក្តីសោមនស្សយ៉ាងក្រៃលែង និងធ្វើការវាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច ឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញទាំងអស់នៃ **ន.ប.ធ.** ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងទទួលខុសត្រូវខ្ពស់លើការអនុវត្តតួនាទី និងការងាររបស់ខ្លួន ដើម្បីកសាងវិស័យបរធនបាលកិច្ចសំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនប្រកបដោយចីរភាព។

ថ្ងៃព្រហស្បតិ៍ ១២ កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

សាររបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ....២
បញ្ជីពាក្យកាត់.... ៧

ផ្នែកទី១

និន្នាការទូទៅនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

ផ្នែកទី២

និយ័តករបរធនបាលកិច្ច

២.១. និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ច.... ១១
២.២. រចនាសម្ព័ន្ធរបស់និយ័តករបរធនបាលកិច្ច....១២
២.៣. ចក្ខុវិស័យ បេសកកម្ម និងមុខងារ....១៣
២.៤. តួនាទី និងភារកិច្ចរបស់ ន.ប.ធ.... ១៤

ផ្នែកទី៣

និន្នាការទីផ្សារបរធនបាលកិច្ច ឆ្នាំ២០២៤

៣.១. បរធនបាលកិច្ចចុះបញ្ជី.... ១៥
៣.២. ប្រតិបត្តិករក្នុងទីផ្សារបរធនបាលកិច្ច....២០

ផ្នែកទី៤

សមិទ្ធផលសំខាន់ៗក្នុងវិស័យបរធនបាលកិច្ច ឆ្នាំ២០២៤

៤.១. ការវិវត្តនៃក្របខ័ណ្ឌច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធគតិយុត្តក្នុងវិស័យបរធនបាលកិច្ច....២៦
៤.១.១. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ.... ២៦
៤.១.២. ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ និងផែនការអភិវឌ្ឍន៍ស្ថាប័ន.... ៣០
៤.១.៣. ក្របខ័ណ្ឌគាំទ្រមុខងារស្ថាប័ន.... ៣៤
៤.២. ការបង្កើតកិច្ចសហប្រតិបត្តិការ....៣៥
៤.៣. ការពង្រឹងសមត្ថភាពស្ថាប័ន.... ៤០
៤.៣.១. ការគ្រប់គ្រងធនធានមនុស្ស និងកិច្ចការរដ្ឋបាល....៤០
៤.៣.២. ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ....៤៩
៤.៣.៣. ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា....៥០
៤.៤. ការជំរុញ និងការអនុវត្តច្បាប់....៥២
៤.៤.១. ការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច.... ៥២
៤.៤.២. ការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច.... ៥២
៤.៤.៣. កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច.... ៥៣
៤.៤.៤. កិច្ចការនីតិកម្ម....៥៥

**៤.៥. ការបណ្តុះបណ្តាល អប់រំ និងផ្សព្វផ្សាយ ..... ៥៥**
៤.៥.១. ការបណ្តុះបណ្តាល និងអប់រំ ..... ៥៥
៤.៥.១.១. កម្មវិធីបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិ និងការអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច ៥៥
៤.៥.១.២.ការបញ្ជ្រាបការយល់ដឹងជាសាធារណៈ ..... ៥៧
៤.៥.២. ការផ្សព្វផ្សាយ ..... ៧៧
៤.៥.២.១. ការរៀបចំរបាយការណ៍ និងបោះពុម្ព ..... ៧៧
៤.៥.២.២. ការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ ..... ៨១
**៤.៦. សមិទ្ធផលផ្សេងៗ ..... ៨២**
៤.៦.១. ការអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម ..... ៨២
៤.៦.២. កម្មវិធីសង្គម ..... ៨៩

## ផ្នែកទី៥
## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖ ក្របខណ្ឌបទដ្ឋានគតិយុត្តក្នុងវិស័យបរធនបាលកិច្ច ..... ៩៤**
**ឧបសម្ព័ន្ធទី២៖ ព្រឹត្តិការណ៍សំខាន់ៗក្នុងវិស័យបរធនបាលកិច្ច ..... ៩៧**
**ឧបសម្ព័ន្ធទី៣៖ ប្រតិបត្តិករក្នុងវិស័យបរធនបាលកិច្ច ..... ១០១**

# បញ្ជីពាក្យកាត់

| ពាក្យកាត់ | ពាក្យពេញ | ពាក្យជាភាសាអង់គ្លេស |
|---|---|---|
| ន.ប.ធ. | និយ័តករបរធនបាលកិច្ច | Trust Regulator |
| អ.ស.ហ. | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | Non-Bank Financial Services Authority |
| ACSEP | គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម | Agricultural Value Chain Competitiveness and Safety Enhancement Project |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AML/CFT/CPF | ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | Anti-Money Laundering, Combating the Financing of Terrorism and Combating Proliferation Financing |
| CAFIU | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |

# ផ្នែកទី១

## ទិដ្ឋភាពទូទៅនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

ក្នុងរយៈពេល ២៥ ឆ្នាំ ចុងក្រោយនេះ ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បាននាំមកជូនប្រទេសជាតិ និងប្រជាជន តាមរយៈ **នយោបាយ ឈ្នះ-ឈ្នះ** កម្ពុជា សម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបានផ្លាស់ប្តូរមុខមាត់គួរជាទីមោទនៈ។ ទោះស្ថិតនៅក្នុងបរិការណ៍នៃការរីករាលដាលនៃវិបត្តិកូវីដ-១៩ រាជរដ្ឋាភិបាល បានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងវិធានការជាបន្តបន្ទាប់ លើផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីពង្រីកការអភិវឌ្ឍវិស័យឯកជន និងសាធារណៈ តាមរយៈការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការទាក់ទាញវិនិយោគិនបរទេស និងជំរុញពាណិជ្ជកម្ម សំដៅពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាបន្ន និងសមធម៌សំដៅលើកកម្ពស់ជីវភាពប្រជាជននិងកាត់បន្ថយភាពក្រីក្រ បាននាំកម្ពុជាឈានចូលរបត់ថ្មីនៃប្រវត្តិសាស្ត្រដោយបានប្រែក្លាយមុខមាត់កម្ពុជាពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងបាននិងកំពុងបន្តចក្ខុវិស័យក្នុងការប្រែក្លាយជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ដែលនេះជាសក្ខីភាពមួយសបញ្ជាក់ឱ្យឃើញពីសមិទ្ធផល និងសក្តានុពលនៃការអភិវឌ្ឍរបស់កម្ពុជា។

មុនវិបត្តិកូវីដ-១៩ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចលឿនជាងគេមួយនៅក្នុងពិភពលោក ក្នុងអត្រា ៨%។ កំណើនខ្ពស់នេះត្រូវបានទ្រទ្រង់ដោយវិស័យចម្បងៗ រួមមាន៖ វិស័យកម្មន្តសាល កសិកម្ម សំណង់ អចលនទ្រព្យ ទេសចរណ៍ និងសេវាកម្មគាំទ្រផ្សេងទៀត ស្របពេលដែលលំហូរវិនិយោគទុនពីបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សកម្មភាពវិនិយោគក្នុងប្រទេស។ ជាមួយគ្នានេះ ការដាក់ចេញនិងការបន្តអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ រួមមាន៖ យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងកម្មវិធីកែទម្រង់ចម្បងៗ ក៏បានក្លាយជាចលករក្នុងការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក និងអភិវឌ្ឍសេដ្ឋកិច្ចនាពេលកន្លងទៅ។

កំណើនសេដ្ឋកិច្ចកម្ពុជា (២០១១-២០២៨)




ប្រភព៖ ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១១-២០២២) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២០២៣-២០២៤)
ចំណាំ៖ ទិន្នន័យ ផ.ស.ស. ឆ្នាំគោលថ្មី ២០១៤

ទោះយ៉ាងណា ការថយចុះនៃសន្ទុះកំណើនសេដ្ឋកិច្ចពិភពលោក ដោយសារវិបត្តិកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងទៀត បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យដែលពឹងផ្អែកលើតម្រូវការខាងក្រៅ និងវិនិយោគផ្ទាល់ពីបរទេស ដូចជា៖ វិស័យ

វាយនភ័ណ្ឌ កាត់ដេរ សំណង់ អចលនទ្រព្យ និងទេសចរណ៍ ដែលសុទ្ធសឹងជាវិស័យចន្ទល់កំណើន ទទួលរងផលប៉ះពាល់។ កត្តាទាំងនេះបាននាំឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះក្នុងអត្រា -៣,៦% នាឆ្នាំ២០២០។ កម្ពុជាបានយកជ័យជម្នះលើសមរភូមិនេះ ដោយម្យ៉ាងដណ្ដើមបានជោគជ័យលើការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ និងម្យ៉ាងទៀតបានជួយស្រោចស្រង់វិស័យឯកជនឱ្យបន្តអាជីវកម្ម និងជំរុញសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ច ព្រមទាំងរក្សាបានលំនឹងជីវភាពរស់នៅរបស់កម្មករនិយោជិត ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ តាមរយៈការដាក់ចេញ និងអនុវត្ត **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣"**។ ជាលទ្ធផល សកម្មភាពសង្គម-សេដ្ឋកិច្ចកម្ពុជាបានវិលត្រលប់ទៅរកប្រក្រតីភាព បន្ទាប់ពីការបើកប្រទេសទាំងស្រុងឡើងវិញ ចាប់ពីចុងឆ្នាំ២០២១ ហើយសេដ្ឋកិច្ចក៏បានងើបឡើងជាលំដាប់ផងដែរ។ ជាក់ស្តែង សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនក្នុងអត្រា ៣,១% នាឆ្នាំ២០២១ ហើយបន្តកើនឡើងដល់ ៥,១% នាឆ្នាំ២០២២ និង ៥,០% នាឆ្នាំ២០២៣ ព្រមទាំងត្រូវបានព្យាករថាមានអត្រា ៦,០% នាឆ្នាំ២០២៤។ ការងើបឡើងនេះ ត្រូវបានគាំទ្រដោយចម្បងដោយកំណើនវិស័យកាត់ដេរ ទេសចរណ៍ និងសេវាគាំទ្រផ្សេងៗ គួបផ្សំនឹងការកើនឡើងនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ (ផ្ទាំងសូឡា សំបកកង់ គ្រឿងសង្ហារឹម គ្រឿងបង្គុំអេឡិចត្រូនិក ដំឡើងរថយន្ត និងឧស្សាហកម្មកែច្នៃមួយចំនួនទៀត) ដែលជាវិស័យទើបលេចចេញថ្មីនិងមានសក្តានុពល។

ទន្ទឹមនឹងទស្សនវិស័យវិជ្ជមានចំពោះសេដ្ឋកិច្ចកម្ពុជា ហានិភ័យមួយចំនួនអាចបន្តគំរាមកំហែងលើសម្ទុះកំណើន រួមមាន៖ **១-** តានតឹងភូមិសាស្ត្រនយោបាយ និងការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច **២-**ការបន្តថមថយកំណើនសេដ្ឋកិច្ចប្រទេសចិន **៣-** ការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុយឺតជាងការរំពឹងទុក និង **៤-**ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។

ស្ថានភាពអតិផរណា ចាប់តាំងពីឆ្នាំ២០១២ មកបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ដោយអត្រាអតិផរណាមានការប្រែប្រួល ក្នុងចន្លោះពី ១,២% (ក្នុងឆ្នាំ២០១៥) ទៅ ៣,៩% (ក្នុងឆ្នាំ២០១៤) ប៉ុណ្ណោះ។ ទោះយ៉ាងណានាឆ្នាំ២០២២ អត្រាអតិផរណាបានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងកម្រិត ៥,៣% ដែលបណ្តាលមកពីការកើនឡើងយ៉ាងគំហុកនៃថ្លៃប្រេងអន្តរជាតិ និងម្ហូបអាហារ។ ការធ្លាក់ចុះក្រុមទំនិញទាំងពីរនេះនាឆ្នាំ២០២៣ បាននាំឱ្យអត្រាអតិផរណាថយចុះមកវិញត្រឹម ២,១%។ ទោះយ៉ាងណា ការបន្តអូសបន្លាយនៃភាពតានតឹងភូមិសាស្ត្រនយោបាយ នៅតែជាហានិភ័យដល់ការកើនឡើងវិញនៃអតិផរណា។ ក្រោមរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង និងក្នុងបរិការណ៍ដុល្លារូបនីយកម្មខ្ពស់ នយោបាយរូបិយវត្ថុមានឥទ្ធិពលមិនពេញលេញក្នុងការគ្រប់គ្រងអតិផរណានោះទេ ដែលទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីនយោបាយសារពើពន្ធ និងការកែទម្រង់រចនាសម្ព័ន្ធ។

អត្រាអតិផរណា (២០១១-២០២៤)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១១-២០២៣) ធនាគារជាតិនៃកម្ពុជា (២០២៤)

គោលដៅចម្បងនៃនយោបាយរូបិយវត្ថុ គឺការរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

របស់កម្ពុជា។ កន្លងមក ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាមេរិកបានចូលរួមរក្សាអត្រាអតិផរណាឱ្យស្ថិតក្នុងកម្រិតទាប និងមានស្ថិរភាព។ នាពេលខាងមុខ ការបង្កើនភាពបត់បែននៃអត្រាប្តូរប្រាក់នឹងបង្កើនសមត្ថភាពនយោបាយរូបិយវត្ថុដែលនឹងជួយដល់ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិផងដែរ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តវិធានការមួយចំនួនដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាមួយនឹងការបន្តការកែទម្រង់ចាំបាច់ ដែលជំរុញសម្ទុះនៃការប្រើប្រាស់ប្រាក់រៀល និងបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ក្នុងបរិការណ៍នៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ប្រព័ន្ធឌីជីថល និងនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុត្រូវបានចាត់ទុកថានឹងរួមចំណែកយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។ ឧស្សាហកម្ម ៤.0 ត្រូវបានរំពឹងថានឹងនាំមកនូវបដិវត្តន៍នៅក្នុងដំណើរការនៃប្រព័ន្ធផលិតកម្ម ស្របពេលដែលហេដ្ឋារចនាសម្ព័ន្ធឌីជីថលក៏រំពឹងថានឹងផ្តល់នូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពខ្ពស់ ក្នុងការបង្កើនលទ្ធភាពស្វែងរកប្រាក់ចំណេញ កាត់បន្ថយការចំណាយ ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព សន្តិសុខនិងសុវត្ថិភាព និងគុណភាពនៃសេវានិងផលិតផលហិរញ្ញវត្ថុ។ តាមរយៈនេះ ការទទួលយកឧស្សាហកម្ម ៤.0 នឹងជួយបង្កើនផលិតភាព ភាពប្រកួតប្រជែង និងប្រាក់ឈ្នួល ផងដែរ។

កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សុខុមាលភាពសង្គមប្រកបដោយសមធម៌និងចីរភាពអាចសម្រេចទៅបានដរាបណាកម្ពុជាអាចបន្តធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនេះទៀតសោត ទាមទារឱ្យខានតែបាននូវការសម្របសម្រួលរវាងនយោបាយរូបិយវត្ថុនិងសារពើពន្ធ របបអត្រាប្តូរប្រាក់និងវិនិយោគសមស្រប ព្រមទាំងភាពរឹងមាំនៃបទប្បញ្ញត្តិនិងការត្រួតពិនិត្យក្នុងវិស័យហិរញ្ញវត្ថុ។

# ផ្នែកទី២

# និយ័តករបរធនបាលកិច្ច

## ២.១. និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ច

និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ច **ន.ប.ធ.** មានរូបហង្សពណ៌មាសឈរនៅចំកណ្តាលរូបបាតដៃទាំងបី ដែលមាន ពណ៌ខៀវ ពណ៌មាស និងពណ៌បៃតង ស្រាក់ចូលគ្នា។ ផ្នែកខាងលើនៃនិមិត្តសញ្ញា មានអក្សរពណ៌ខៀវ "**និយ័តករបរធនបាលកិច្ច**" និងខាងក្រោមមានអក្សរ "TRUST REGULATOR"។

### អត្ថន័យ
### និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ច

១ រូបហង្សពណ៌មាស៖ តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យ គ្រប់គ្រង និងអភិវឌ្ឍវិស័យបរធនបាលកិច្ច និងធានាឱ្យដំណើរការប្រតិបត្តិការបរធនបាលកិច្ចប្រកប ដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។

២ រូបហង្សពណ៌មាស ឈរពីលើរូបបាតដៃទាំងបី ដែលមានពណ៌ខៀវ ពណ៌មាស និង ពណ៌បៃតង ស្រាក់ចូលគ្នា៖ បង្ហាញថា ប្រតិបត្តិការបរធនបាលកិច្ចស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់និយ័តករបរធនបាលកិច្ចប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។

៣ រូបបាតដៃទាំងបី ដែលមានពណ៌ខៀវ ពណ៌មាស និងពណ៌បៃតង ស្រាក់ចូលគ្នា៖ តំណាងឱ្យប្រតិបត្តិការបរធនបាលកិច្ច ដែលក្នុងនោះបរធនបាល គ្រប់គ្រង និង ចាត់ចែងបរធន ដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ។

៤ រូបស្លឹកឈើ៖ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យបរធនបាលកិច្ចក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ២.២. រចនាសម្ព័ន្ធរបស់និយ័តករបរធនបាលកិច្ច

យោងតាមអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពី "ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" និងប្រកាសលេខ ០០៦ អ.ស.ហ. ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្ដីពី "ការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច" **ន.ប.ធ.** ត្រូវដឹកនាំដោយអគ្គនាយក ចំនួន ១ រូប អមដោយអគ្គនាយករងមួយចំនួន និងមាននាយកដ្ឋានចំណុះ ចំនួន ៤ រួមមាន៖ នាយកដ្ឋានកិច្ចការទូទៅ, នាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច, នាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ ដែលនាយកដ្ឋាននីមួយៗមានការិយាល័យចំណុះចំនួន ៣។



## ២.៣. ចក្ខុវិស័យ បេសកកម្ម និងមុខងារ



**ចក្ខុវិស័យ**

**ន.ប.ធ.** ជាស្ថាប័នមួយមានចក្ខុវិស័យក្លាយជាស្ថាប័នស្នូលមានសមត្ថភាព និងវិជ្ជាជីវៈ ស្ថិតក្រោមការអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកដល់ការបង្កើនចំណូលពន្ធជាតិ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិនាថ្ងៃអនាគតតាមរយៈយន្តការបរធនបាលកិច្ច។ **ន.ប.ធ.** មានកិច្ចដំណើរការប្រកបដោយនិរន្តរភាព និងគណនេយ្យភាព ដោយទទួលបាននូវការទុកចិត្តពីរាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គពាក់ព័ន្ធ ដើម្បីទ្រទ្រង់ និងគាំពារការអភិវឌ្ឍក្នុងវិស័យបរធនបាលកិច្ច សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមប្រកបដោយចីរភាព និងបរិយាបន្ន ដោយបរធនបាលកិច្ច ជាយន្តការ និងថ្នាលបង្កើនទំនុកចិត្តបន្ថែមក្នុងធុរកិច្ច ព្រមទាំងក្លាយជាយន្តការដែលជួយបង្កើនការទាក់ទាញការវិនិយោគ និងកៀរគរវិនិយោគិនមកប្រទេសកម្ពុជា។



**បេសកកម្ម**

ក្នុងការបំពេញមុខងារ និងភារកិច្ច **ន.ប.ធ.** មានបេសកកម្មចម្បងចំនួន បី ដូចតទៅ៖

- បង្កើត និងផ្តល់នូវថ្នាលទំនុកចិត្តក្នុងធុរកិច្ច និងទាក់ទាញរាល់ការវិនិយោគពាក់ព័ន្ធមកកម្ពុជាដែលជាប្រភពនៃការបន្ថែមចំណូលពន្ធជាតិ
- ជំរុញការធ្វើពិពិកម្មហិរញ្ញវត្ថុទាំងក្នុងក្របខ័ណ្ឌ ប្រតិបត្តិការទីផ្សារ ផលិតផល សេវាកម្ម និងនវានុវត្តន៍បច្ចេកវិទ្យា ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា
- ផ្តល់លទ្ធភាព និងយន្តការក្នុងការងារតាមដាន និងគ្រប់គ្រងនូវរំហូរទុនដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធ។



**មុខងារ**

**ន.ប.ធ.** ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលនៅក្នុងនោះ **ន.ប.ធ.** ត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជានិយ័តករ គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ស្តីពី បរធនបាលកិច្ច ដែលត្រូវបានប្រកាស ឱ្យប្រើនៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ២.៤. តួនាទី និងភារកិច្ចរបស់ ន.ប.ធ.

យោងតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច ត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច និងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យបរធនបាលកិច្ច
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការចុះបញ្ជីបរធនបាលកិច្ច ការផ្តល់ការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករជាបរធន-បាល និងអ្នកចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច
- រៀបចំ និងធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការអនុញ្ញាត និង/ឬការចុះបញ្ជីរូបវន្តបុគ្គល/នីតិបុគ្គល ដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- គ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យបរធន-បាលកិច្ច តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងរៀបចំថវិការបស់ **ន.ប.ធ.** ជាមួយអគ្គលេខាធិការដ្ឋាន
- ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យបរធនបាលកិច្ច
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការចុះបញ្ជីបរធនបាលកិច្ចដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា រួមទាំងការកំណត់នូវការបែងចែករវាងបរធននិងបរធនវិនិយោគនៃគម្រោងវិនិយោគរួម ដែលស្ថិតក្រោមនិយ័តកម្មនៃវិស័យមូលបត្រ
- ពិនិត្យ និងស្នើសុំរៀបចំក្រុមប្រឹក្សាដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ប.ធ.**
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ប.ធ.** និងរៀបចំបញ្ជីសារពើភ័ណ្ឌជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

# ផ្នែកទី៣
# ទិន្នន័យទីផ្សារបរធនបាលកិច្ច ឆ្នាំ២០២៤

## ៣.១. បរធនបាលកិច្ចចុះបញ្ជី

រាល់ការបង្កើតបរធនបាលកិច្ចទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបង្កើតជាមុន និងការអនុញ្ញាតចុះបញ្ជីពី **ន.ប.ធ.** ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### នីតិវិធីនៃការបង្កើតបរធនបាលកិច្ច

- **ជំហានទី១៖** ជ្រើសតាំងបរធនបាល
- **ជំហានទី២៖** ចុះហត្ថលេខាលើលិខិតបរធនបាលកិច្ច
- **ជំហានទី៣៖** បំពេញពាក្យស្នើសុំ
- **ជំហានទី៤៖** ដាក់ពាក្យស្នើសុំបង្កើត

### នីតិវិធីនៃការចុះបញ្ជីបរធនបាលកិច្ច

- **ជំហានទី១៖** បំពេញពាក្យស្នើសុំ
- **ជំហានទី២៖** ដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ច
- **ជំហានទី៣៖** ពិនិត្យពាក្យស្នើសុំ និងបង់កម្រៃសេវាចុះបញ្ជីបរធនបាលកិច្ច
- **ជំហានទី៤៖** ចេញសេចក្តីសម្រេច និងវិញ្ញាបនបត្រចុះបញ្ជី

### យន្តការ ចុះបញ្ជីបរធនបាលកិច្ច

### ការគ្រប់គ្រង និងត្រួតពិនិត្យ

- ❖ ក្នុងអំឡុងរយៈពេលកំណត់នៃបរធនបាលកិច្ច បរធនបាលមានកាតព្វកិច្ចសំខាន់ៗ មានដូចជា៖
  - ❑ ផ្តល់របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចទៅតាមការកំណត់របស់ **ន.ប.ធ.**
  - ❑ ដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចក្នុងរយៈពេលយ៉ាងតិច ៦០ ថ្ងៃ មុនសុពលភាពចាស់ផុតកំណត់ និងបង់ថ្លៃសោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំ ទៅតាមទំហំបរធន
- ❖ សុពលភាពនៃបរធនបាលកិច្ច ត្រូវបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច ឬតាមការកំណត់របស់ **ន.ប.ធ.**
- ❖ បរធនបាល ត្រូវស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចមុនពេលវិញ្ញាបនបត្រអស់សុពលភាព ដោយត្រូវស្នើសុំ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ប.ធ.**
- ❖ ការស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច បរធនបាលត្រូវបង់ថ្លៃពាក្យស្នើសុំបន្តចំនួន ២០.០០០ រៀល និងថ្លៃសេវាចុះបញ្ជីបរធនបាលកិច្ច (កម្រៃរដ្ឋបាល&សោហ៊ុយវិញ្ញាបនបត្រ) ដោយផ្អែកលើសមតុល្យបរធននៃឆ្នាំសារពើពន្ធ។

### ការបញ្ចប់

- ❖ ការមកដល់នៃកាលវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច
- ❖ ការសម្រេចគោលបំណងរបស់បរធនបាលកិច្ច
- ❖ ការសម្រេចដោយឆន្ទានុសិទ្ធិឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក
- ❖ តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬ
- ❖ តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

ចាប់តាំងពីការបង្កើត **ន.ប.ធ.** នៅឆ្នាំ២០២១ និងការប្រកាសពីការបង្កើតបាននូវអត្តិភាពទីផ្សារបរធនបាលកិច្ច ជាមួយនឹងប្រតិបត្តិការពេញលេញដោយជោគជ័យ នៅដើមឆ្នាំ២០២៣ កំណើននៃការចុះបញ្ជីបរធនបាលកិច្ច មានការកើនឡើងយ៉ាងឆាប់រហ័ស ដោយចំនួនបរធនបាលកិច្ចដែលបានបង្កើត និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់ បានកើនឡើងពី ១៧ ករណី ជាមួយទំហំបរធនសរុបចំនួនប្រមាណ ១៥៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដល់ចំនួន ១,១១៥ ករណី ជាមួយទំហំបរធនសរុបចំនួនប្រមាណ ១,៧៤១ លានដុល្លារអាមេរិក គិតត្រឹមឆ្នាំ២០២៤។

**កំណើនចំនួនបរធនបាលកិច្ច**



**1,115**
**Cases**

**កំណើនទំហំបរធន**




**$ 1,741**
**Billion**







**ឆ្នាំ ២០២១**
ចំនួនបរធនបាលកិច្ចចុះបញ្ជី ១៧ ករណី ជាមួយទំហំបរធន ១៥៦ លានដុល្លារអាមេរិក

**ឆ្នាំ ២០២២**
ចំនួនបរធនបាលកិច្ចចុះបញ្ជី ៣០២ ករណី ជាមួយទំហំបរធន ៧៩៩ លានដុល្លារអាមេរិក

**ឆ្នាំ ២០២៣**
ចំនួនបរធនបាលកិច្ចចុះបញ្ជី ៧៨៨ ករណី ជាមួយទំហំបរធន ១,២៧១ លានដុល្លារអាមេរិក

**ឆ្នាំ ២០២៤**
ចំនួនបរធនបាលកិច្ចចុះបញ្ជី ១,១១៥ ករណី ជាមួយទំហំបរធន ១,៧៤១ លានដុល្លារអាមេរិក

# កំណើនចំនួនបរធនបាលកិច្ចដែលបានចុះបញ្ជី ឆ្នាំ២០២៤

**ចំនួនបរធនបាលកិច្ចដែលបានចុះបញ្ជី**

**៣២៦ ករណី**

**ទំហំបរធនដែលបានចុះបញ្ជី**

**៤៣១,០៦២,៦០១.២៣ ដុល្លារអាមេរិក**

| ល.រ. | ប្រភេទបរធនបាលកិច្ច | ចំនួន | ទំហំបរធន |
|---|---|---|---|
| ១ | បរធនបាលកិច្ចសាធារណៈ | 2 | $ 12,722,059.50 |
| ២ | បរធនបាលកិច្ចបុគ្គល | 1 | $ 80,800.00 |
| ៣ | បរធនបាលកិច្ចពាណិជ្ជកម្ម | 323 | $ 418,259,741.73 |
| | សរុប | 326 | $ 431,062,601.23 |



# កំណើនបរធនបាលកិច្ចពាណិជ្ជកម្ម
# ដែលបានចុះបញ្ជី ឆ្នាំ២០២៤






## ទំហំបរធនដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់
## (ក្នុងឆ្នាំ២០២៤)




| ល.រ. | ប្រភេទបរធនបាលកិច្ច | ទំហំបរធន |
|---|---|---|
| ១ | បរធនបាលកិច្ចសាធារណៈ | $ 12,722,059.50 |
| ២ | បរធនបាលកិច្ចហិរញ្ញវត្ថុ | $ - |
| ៣ | បរធនបាលកិច្ចសង្គម | $ - |
| ៤ | បរធនបាលកិច្ចបុគ្គល | $ 80,800.00 |
| ៥ | អចលនវត្ថុ | $ 121,762,808.70 |
| ៦ | សេវារក្សាសុវត្ថិភាព ឬរក្សាទុក | $ 259,710,464.20 |

| ល.រ. | ប្រភេទបរធនបាលកិច្ច | ទំហំបរធន |
|---|---|---|
| ៧ | ប្រាក់បញ្ញើមានកាលកំណត់ | $ 1,230,000.00 |
| ៨ | មូលនិធិសោធនិវត្តន៍ឯកជន | $ 28,209,449.83 |
| ៩ | មូលនិធិភាគហ៊ុនិក | $ 7,327,019.00 |
| ១០ | សញ្ញាបណ្ណបៃតង | $ - |
| ១១ | មូលនិធិសាច់ប្រាក់ | $ 20,000.00 |
| ទំហំបរធនសរុបក្នុងឆ្នាំ២០២៤ | | $ 431,062,601.23 |

## ទំហំបរធននៃបរធនបាលកិច្ចអចលនវត្ថុ
## ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់
## (ក្នុងឆ្នាំ២០២៤)




## ទំហំបរធននៃបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬរក្សាទុក
## ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់
## (ក្នុងឆ្នាំ២០២៤)



## ៣.២. ប្រតិបត្តិករក្នុងទីផ្សារបរធនបាលកិច្ច

ក្នុងឆ្នាំ២០២៤ នេះ វិស័យបរធនបាលកិច្ចនៅកម្ពុជា មានតួអង្គ និងប្រតិបត្តិករពាក់ព័ន្ធ ចំនួន ៦ រួមមាន៖ **១**-ក្រុមហ៊ុនបរធនបាល, **២**-ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, **៣**-បរធនបាលរូបវន្តបុគ្គលឯករាជ្យ, **៤**-បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល, **៥**-ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និង **៦**-ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច។

### ក្រុមហ៊ុនបរធនបាល

សំដៅដល់បរធនបាលជានីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **ន.ម.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន។ ក្នុងឆ្នាំ២០២៤ នេះ **ន.ម.ធ.** បានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនបរធនបាល **ចំនួន ៤** គឺ ក្រុមហ៊ុន អេស អ៊ិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក, ក្រុមហ៊ុន ស៊ីស៊ីយូ ត្រាស់ ឯ.ក, ក្រុមហ៊ុន អ៊ិកស៍ ត្រាស់ ឯ.ក និងក្រុមហ៊ុន អវតា គ្លូបិល វេនឈ័រ ឯ.ក។

SM Global Trust & Investment Management Co., Ltd.

- **ឈ្មោះ៖** ក្រុមហ៊ុន អេស អ៊ិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** បរធនបាលកិច្ចពាណិជ្ជកម្ម និង បរធនបាលកិច្ចសង្គម
- **ទីស្នាក់ការ៖** អគារលេខ៥៣ បន្ទប់លេខ២៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចកខណ្ឌដូនពេញ រាជធានីភ្នំពេញ
- **លេខទូរស័ព្ទ៖** (855) 23 990 853
- **អ៊ីមែល ៖** savda@smacct.com

CCUtrust

- **ឈ្មោះ៖** ក្រុមហ៊ុន ស៊ីស៊ីយូ ត្រាស់ ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** បរធនបាលកិច្ចពាណិជ្ជកម្ម
- **ទីស្នាក់ការ៖** អគារលេខ GS-០៧ ជាន់ទី ៦ មហាវិថីព្រះសីហនុ (ផ្លូវលេខ ២៧៤) ភូមិ ៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
- **លេខទូរស័ព្ទ៖** (855) 96 7 218 777
- **អ៊ីម៉ែល ៖** info@ccutrust.com.kh

អ៊ិកស៍ ត្រាស់ ឯ.ក
X TRUST Co., Ltd.
X 信 托 公 司

- **ឈ្មោះ៖** ក្រុមហ៊ុន អ៊ិកស៍ ត្រាស់ ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** បរធនបាលកិច្ចពាណិជ្ជកម្ម
- **ទីស្នាក់ការ៖** អគារលេខ១៩០ (ការិយាល័យជាន់ទី៣) ផ្លូវលេខ៥១ ភូមិ៨ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- **លេខទូរស័ព្ទ៖** (855) 23 868 989

អវតារ គ្លូបិលវេនឈ័រ
AVATAR GLOBAL VENTURES

- **ឈ្មោះ៖** ក្រុមហ៊ុន អវតា គ្លូបិល វេនឈ័រ ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** បរធនបាលកិច្ចពាណិជ្ជកម្ម
- **ទីស្នាក់ការ៖** អគារលេខ៣៧-R៤, ផ្លូវលេខ2360, ភូមិ១, សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- **លេខទូរស័ព្ទ៖** (855) 12 772 771
- **អ៊ីម៉ែល ៖** huy@avatar-globalventures.com.kh

## ប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច

សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) សំដៅដល់ប្រតិបត្តិការដែលក្នុងនោះ ម្ចាស់ទ្រព្យបានប្រគល់ទ្រព្យ របស់ខ្លួនឱ្យទៅធនាគារពាណិជ្ជ ដែលទទួលបានអាជ្ញាបណ្ណឬការអនុញ្ញាតពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច ដើម្បីរក្សាសុវត្ថិភាព ឬរក្សាទុក តាមរយៈការបង្កើតគណនី Escrow ក្នុងគោលបំណងដើម្បីធ្វើការទូទាត់ ឬប្រគល់ទ្រព្យនោះទៅឱ្យបុគ្គលណាមួយ ក្នុងប្រតិបត្តិការធុរកិច្ច ឬក្នុងប្រតិបត្តិការអចលនទ្រព្យ ឬក្នុងប្រតិបត្តិការវិនិយោគនានា នៅពេលកំណត់ជាក់លាក់ណាមួយ តាមលក្ខខ័ណ្ឌដែលបានព្រមព្រៀង។

ប្រតិបត្តិការសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ដែលមានអនុលោមភាពតាមច្បាប់ និងចុះបញ្ជីបរធនបាលកិច្ចត្រឹមត្រូវ ផ្ដល់នូវអត្ថប្រយោជន៍មួយចំនួនរួមមាន៖

- ❖ អាចជួយការពារហានិភ័យ បង្កើតទំនុកចិត្ត និងបង្កើនសុវត្ថិភាពដល់ភាគីពាក់ព័ន្ធ និង
- ❖ មានអនុលោមភាព និងការគាំពារដោយច្បាប់ និងមាននិយ័តករធ្វើការតាមដាន និងត្រួតពិនិត្យទៅលើប្រតិបត្តិការនោះ។

យោងតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ធនាគារពាណិជ្ជដែលអាចធ្វើជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច ត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**។






- **ឆ្នាំ២០២២៖ ន.ប.ធ.** បានផ្ដល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ធនាគារពាណិជ្ជ ចំនួន ៤ ធនាគារ
- **ឆ្នាំ២០២៣៖ ន.ប.ធ.** បានផ្ដល់អាជ្ញាបណ្ណដល់ធនាគារពាណិជ្ជ ចំនួន ១០ ធនាគារ
- **ឆ្នាំ២០២៤៖ ន.ប.ធ.** បានផ្ដល់អាជ្ញាបណ្ណដល់ធនាគារពាណិជ្ជ ចំនួន ១១ ធនាគារ

ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានផ្តល់អាជ្ញាបណ្ណដល់ធនាគារពាណិជ្ជចំនួន ១១ ធនាគារ ដើម្បីធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិករបរធន-បាលកិច្ចសាធារណៈ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល។

| ល.រ. | ឈ្មោះធនាគារ | កាលបរិច្ឆេទ ទទួលបានអាជ្ញាបណ្ណ |
|---|---|---|
| ១ | ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក | ១៥ មករា ២០២៤ |
| ២ | ធនាគារ ស៊ីស៊ីយូ ខមមើសល ប៉ែង ម.ក | ១៩ មករា ២០២៤ |
| ៣ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | ២៦ មករា ២០២៤ |
| ៤ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | ២៨ មេសា ២០២៤ |
| ៥ | ធនាគារ សហពាណិជ្ជ ក.អ | ២៣ កក្កដា ២០២៤ |
| ៦ | ធនាគារ ពាណិជ្ជ អាល់ហ្វា ម.ក | ២ សីហា ២០២៤ |
| ៧ | ធនាគារ វឌ្ឍនៈ | ១៣ សីហា ២០២៤ |
| ៨ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | ២០ សីហា ២០២៤ |
| ៩ | ធនាគារ អូរៀនថល ម.ក | ១៦ តុលា ២០២៤ |
| ១០ | សាជីវកម្មធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ | ២ ធ្នូ ២០២៤ |
| ១១ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ១២ ធ្នូ ២០២៤ |

## ការផ្តល់អាជ្ញាបណ្ណដល់បរធនបាលរូបវន្តបុគ្គល

- **បរធនបាលរូបវន្តបុគ្គលឯករាជ្យ៖** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិតនៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាលណាមួយឡើយ។
- **បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល៖** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើជារូបវន្តបុគ្គលក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាល។

គិតត្រឹមឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានផ្តល់អាជ្ញាបណ្ណដល់បរធនបាលរូបវន្តបុគ្គលឯករាជ្យ ដើម្បីធ្វើប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងវិស័យបរធនបាលកិច្ចចំនួន ៣១ រូប ដែលក្នុងនោះរួមមាន អ្នកជំនាញផ្នែកហិរញ្ញវត្ថុ អ្នកជំនាញគ្រប់គ្រងក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ អ្នកជំនាញផ្នែកច្បាប់ និងមេធាវីជាដើម។ លើសពីនេះ **ន.ប.ធ.** ក៏បានផ្តល់អាជ្ញាបណ្ណដល់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលចំនួន ៣៦ រូប ផងដែរ ដើម្បីតំណាងឱ្យក្រុមហ៊ុនបរធនបាល ក្នុងការធ្វើប្រតិបត្តិការបរធនបាលកិច្ច។

**បរធនបាលរូបវន្តបុគ្គលឯករាជ្យ**




**បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល**






**៤**

**បរធនបាលរូបវន្តបុគ្គលឯករាជ្យ**

ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានផ្តល់អាជ្ញាបណ្ណដល់បរធនបាលរូបវន្តបុគ្គលឯករាជ្យ ដើម្បីធ្វើប្រតិបត្តិការបរធនបាលកិច្ចក្នុងវិស័យបរធនបាលកិច្ចចំនួន ៤ រូប ដែលក្នុងនោះរួមមាន អ្នកជំនាញផ្នែកហិរញ្ញវត្ថុ អ្នកជំនាញគ្រប់គ្រងក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ អ្នកជំនាញផ្នែកច្បាប់ និងមេធាវីជាដើម។



**១០**

**បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល**

ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** ក៏បានផ្តល់អាជ្ញាបណ្ណដល់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលចំនួន ១០ រូប ផងដែរ ដើម្បីតំណាងឱ្យក្រុមហ៊ុនបរធនបាលក្នុងការធ្វើប្រតិបត្តិការបរធនបាលកិច្ច។

## ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច

អនុលោមតាមប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃអចលនវត្ថុ ដែលមានបំណងវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ត្រូវស្នើសុំការទទួលស្គាល់ពី **ន.ប.ធ**. ដែលត្រូវបំពេញលក្ខខ័ណ្ឌ និងនីតិវិធីដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច សំដៅធានាឱ្យបានសុក្រឹត្យភាពនៃតម្លៃបរធនបាលកិច្ច ដែលបានបង្កើត និងចុះបញ្ជីបរធនបាលកិច្ច។

ក្នុងឆ្នាំ២០២៤ **ន.ប.ធ**. បានផ្តល់ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ចចំនួន ៤ ក្រុមហ៊ុន រួមមាន៖

- ❖ ក្រុមហ៊ុន អ៊ែតវ៉ានថិច ប្រផឹធី សឺវីស ឯ.ក
- ❖ ក្រុមហ៊ុន អាយ រៀល អ៊ីស្តេត
- ❖ ក្រុមហ៊ុន ឡាក់ឃី រៀលធី
- ❖ ក្រុមហ៊ុន ផារ៉ាដាយ ប្រផឹធី វ៉ាលូអេសិន អេនធើប្រាយ ឯ.ក។

- **ឈ្មោះ៖** ក្រុមហ៊ុន អ៊ែតវ៉ានថិច ប្រផឹធី សឺវីស ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** វាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច
- **ទីស្នាក់ការ៖** #១៤៦ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ក្រុមហ៊ុន អ៊ែតវ៉ានថិច ប្រផឹធី សឺវីស ឯ.ក

- **ឈ្មោះ៖** ក្រុមហ៊ុន អាយ រៀល អ៊ីស្តេត
- **ប្រភេទប្រតិបត្តិការ៖** វាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច
- **ទីស្នាក់ការ៖** #អគារលេខ C៧ The Fortune Tower ប្រភេទ Office H គំរោង អូឡាំព្យា ស៊ីធី ផ្លូវឧកញ៉ា ទេពផន (១៨២) កែងផ្លូវ១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ក្រុមហ៊ុន អាយ រៀល អ៊ីស្តេត

- **ឈ្មោះ៖** ក្រុមហ៊ុន ឡាក់ឃី រៀលធី
- **ប្រភេទប្រតិបត្តិការ៖** វាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច
- **ទីស្នាក់ការ៖** ផ្ទះលេខ៩ ផ្លូវលេខ៥ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ក្រុមហ៊ុន ឡាក់ឃី រៀលធី

- **ឈ្មោះ៖** ក្រុមហ៊ុន ផារ៉ាដាយ ប្រផឹធី វ៉ាលូអេសិន អេនធើប្រាយ ឯ.ក
- **ប្រភេទប្រតិបត្តិការ៖** វាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច
- **ទីស្នាក់ការ៖** អគារ Morgan Tower, Unit5 ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ក្រុមហ៊ុន ផារ៉ាដាយ ប្រផឹធី វ៉ាលូអេសិន អេនធើប្រាយ ឯ.ក

## ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច

អនុលោមតាមប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលមានបំណងស្នើសុំការទទួលស្គាល់ពី **ន.ម.ឆ.** ត្រូវដាក់ពាក្យស្នើសុំទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ឆ.** ព្រមទាំងបំពេញលក្ខខណ្ឌ និងនីតិវិធី ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

ក្នុងឆ្នាំ២០២៤ **ន.ម.ឆ.** បានផ្តល់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ចំនួន ១៥ ក្រុមហ៊ុន។

Quantum Spectrum – In the Know | PwC | EY – Building a better working world | SM Global Accounting & Consulting Co., Ltd. 에스엠 會計法人

bakertilly | KPMG | Deloitte.

Grant Thornton | BLUE Chartered Accountants and Auditors | Crowe | Fii

BDO | REACHS The Professional Stance | KRESTON CAMBODIA CAM ACCOUNTING & TAX SERVICE CO., LTD.

## ផ្នែកទី៤
## សមិទ្ធផលសំខាន់ៗក្នុងវិស័យបរធនបាលកិច្ច ឆ្នាំ២០២៤

### ៤.១. ការវិវត្តនៃក្របខ័ណ្ឌច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធគតិយុត្តក្នុងវិស័យបរធនបាលកិច្ច

កន្លងមក ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព យុត្តិធម៌ តម្លាភាព និងសណ្តាប់ធ្នាប់ **ន.ប.ធ.** បានរៀបចំ តាក់តែង និងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។ **ន.ប.ធ.** បានរៀបចំ ស្នើឡើង និងអនុវត្តនូវបទដ្ឋានគតិយុត្តកែសម្រួល ដើម្បីគ្រប់គ្រងទីផ្សារបរធនបាលកិច្ចទាំងមូល ដែលក្នុងនោះ ក្រៅពីបរធនបាលកិច្ច តាមប្រភេទផ្សេងៗដែលបានបង្កើតនិងចុះបញ្ជី មានតួអង្គប្រតិបត្តិករ និងអ្នកចូលរួមដទៃក្នុងទីផ្សារបន្ថែមទៀតផងដែរ ដូចជា៖ បរធនបាល និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ចដែលត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពី **ន.ប.ធ.**។ ចាប់តាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ដើម្បីគាំទ្រដល់កិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច **ន.ប.ធ.** បានរៀបចំ និងស្នើឡើងនូវក្របខ័ណ្ឌបទប្បញ្ញត្តិរួមមាន៖ ច្បាប់ចំនួន ២ អនុក្រឹត្យចំនួន ៤ ប្រកាសចំនួន ១៥ និងសេចក្តីសម្រេច សេចក្តីណែនាំ និងគោលការណ៍ណែនាំ ចំនួន ១៧។ តាមរយៈការរៀបចំបទប្បញ្ញត្តិដើម្បីគាំទ្រកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព យុត្តិធម៌ តម្លាភាព និងសណ្តាប់ធ្នាប់ សមិទ្ធផលជារូបវន្តសំខាន់ៗជាច្រើន ត្រូវបានលេចជារូបរាងឡើង។ ក៏ប៉ុន្តែ ដើម្បីបន្តពង្រឹង និងចាប់យកឱកាសពង្រីកទីផ្សារបរធនបាលកិច្ចនៅកម្ពុជា ព្រមទាំងកាត់បន្ថយការអនុវត្តការងារដែលមានភាពខ្វះចន្លោះ ការអភិវឌ្ឍវិស័យបរធនបាលកិច្ចរយៈពេលវែង គឺជាការងារចាំបាច់ និងទាមទារឱ្យមានការរៀបចំកសាងក្របខ័ណ្ឌច្បាប់បទប្បញ្ញត្តិបន្ថែមទៀត ជាពិសេសដោយមានការគិតគូរ និងពិនិត្យរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធវិស័យបរធនបាលកិច្ច ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

#### ៤.១.១. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ

ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់កិច្ចដំណើរការអភិឌ្ឍន៍ក្នុងវិស័យបរធនបាលកិច្ច ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានរៀបចំ ប្រកាស ចំនួន ២ និងគោលការណ៍ណែនាំ ចំនួន ១ រួមមាន៖ ប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនសេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច និងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច ដែលទទួលបានការអនុម័តដាក់ឱ្យប្រើ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤ និងគោលការណ៍ណែនាំស្តីពី ទម្រង់របាយការណ៍របស់បរធនបាល ដែលបានដាក់ឱ្យអនុវត្ត កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥។

**ប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច" ទទួលបានការអនុម័តដាក់ឱ្យប្រើពីប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤**



ប្រកាសនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដល់សាធារណជន, បរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ជាពិសេសក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបំណងដាក់ពាក្យស្នើសុំការទទួលស្គាល់ពី **ន.ប.ធ.** ក្នុងការផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាឱ្យបាននូវគុណភាពសវនកម្ម និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

បន្ថែមពីនេះ ដើម្បីឱ្យប្រកាសនេះ អាចអនុវត្តបានប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្ត **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់ប្រតិបត្តិករ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច រួមមាន៖ ក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** ព្រមទាំងក្រុមហ៊ុនផ្តល់សេវាសវនកម្ម ផងដែរ។










***រូបភាព៖*** សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤។

## ប្រកាសស្ដីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច ទទួលបានការអនុម័តដាក់ឱ្យប្រើពីប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤



ប្រកាសនេះ បានកំណត់អំពីវិធាន បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងការពិន័យអន្តរការណ៍ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ ការអនុញ្ញាត ការចុះបញ្ជី ការទទួលស្គាល់ពី **ន.ប.ធ.** ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចដែលមានជាធរមាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច។

បន្ថែមពីនេះ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## គោលការណ៍ណែនាំស្ដីពី ទម្រង់របាយការណ៍របស់បរធនបាល ដែលបានដាក់ឱ្យអនុវត្ត កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥



គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដើម្បីជួយសម្រួលដល់ការបំពេញកាតព្វកិច្ចផ្ដល់របាយការណ៍ជូនដំណឹង និងការស្នើសុំការអនុញ្ញាតរបស់បរធនបាល ប្រកបដោយសណ្ដាប់ធ្នាប់ និងប្រសិទ្ធភាព។

## ពិធីសម្បថរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់និយ័តករបរធនបាលកិច្ច

អនុលោមតាមប្រកាសអន្តរក្រសួងលេខ ១១៣ កយ.អសហ.ប្រក/២៣ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់ **ន.ប.ធ.** ចំនួន ៨ រូប ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ បានចូលធ្វើពិធីសម្បថនៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ ស្របតាមមាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤។

នគរបាលយុត្តិធម៌នៃ **ន.ប.ធ.** មានសិទ្ធិអំណាច ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីបរធនបាលកិច្ច ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃធ្វើអធិការកិច្ចបរធនបាលកិច្ច ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ចំពោះករណីសង្ស័យប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចជាអាទិ៍ ការប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់ពី **ន.ប.ធ.** ជាដើម។









**រូបភាព៖** ពិធីសម្បថរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់និយ័តករបរធនបាលកិច្ច កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤។

## ៤.១.២. ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ និងផែនការអភិវឌ្ឍន៍ស្ថាប័ន

ក្នុងគោលដៅអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនដូចបានចែងក្នុងអនុក្រឹត្យស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសស្ដីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ បានកំណត់អំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទ **ន.ប.ធ.**, ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច និងផែនការសកម្មភាពបីឆ្នាំរំកិលរបស់ **ន.ប.ធ.** ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។



ផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករបរធនបាលកិច្ចសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) បានធ្វើបច្ចុប្បន្នភាពទៅជា ផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច ដែលទទួលបានការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការពីប្រធានក្រុមប្រឹក្សាភិបាល **អ.ស.ហ.** កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤។ បន្ថែមពីនេះ ការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពបីឆ្នាំរំកិល បានបន្តផ្តោត និងពង្រឹងលើគោលដៅធំៗ ចំនួន បី រួមមានៈ

- ការពង្រឹងសមត្ថភាពស្ថាប័ន
- ការពង្រឹងមុខងារស្ថាប័ន
- ការពង្រឹងសមត្ថភាពគាំទ្រការអភិវឌ្ឍវិស័យបរធនបាលកិច្ច



បន្ថែមពីនេះ ក្នុងគោលដៅដើម្បីបន្តចូលរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" របស់រាជរដ្ឋាភិបាល នីតិកាលអាណត្តិទី៧ នៃរដ្ឋសភា និងដើម្បីទទួលបាននូវក្របខ័ណ្ឌយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យបរធនបាលកិច្ចច្បាស់លាស់សម្រាប់រយៈពេលខ្លី មធ្យម និងវែង **ន.ប.ធ.** បានរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ ដោយផ្តោតជាសំខាន់លើយុទ្ធសាស្ត្រអាទិភាព ចំនួន ៤។




យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើលទ្ធផលនៃការសិក្សា ស្រាវជ្រាវ វិភាគ ពិនិត្យវាយតម្លៃលើរបាយការណ៍ ព័ត៌មាន ទិន្នន័យពីការរៀបចំកិច្ចប្រជុំពិភាក្សាប្រមូលធាតុចូល និងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នរដ្ឋ និងឯកជនពាក់ព័ន្ធ។ ការរៀបចំយុទ្ធសាស្ត្រនេះ ក៏បានផ្អែកលើការប្រមូលធាតុចូលពីស្ថាប័នអន្តរជាតិ ផងដែរ តាមរយៈការធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ពីបណ្តាប្រទេសមួយចំនួន មានដូចជា៖ ប្រទេសថៃ កូរ៉េ សិង្ហបុរី ម៉ាឡេស៊ី ហុងកុង និងប្រទេសឥណ្ឌូនេស៊ី។ បន្ថែមពីនេះ សិក្ខាសាលាពិគ្រោះយោបល់មួយចំនួនត្រូវបានរៀបចំឡើងជាមួយតួអង្គ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច រួមមាន៖ ក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុកក្នុងវិស័យបរធនបាលកិច្ច បរធនបាលរូបវន្តបុគ្គល ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥។




**រូបភាព៖** សិក្ខាសាលាពិគ្រោះយោបល់ទទួលធាតុចូល ចំនួន ៣ លើក លើការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥។

### ៤.១.៣. ក្របខ័ណ្ឌគាំទ្រមុខងារស្ថាប័ន

ក្នុងទិសដៅគ្រប់គ្រង ជំរុញ និងពង្រឹងដល់កិច្ចដំណើរការអនុវត្តការងាររបស់ **ន.ប.ធ.** ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសណ្តាប់ធ្នាប់ល្អ ក្នុងក្របខ័ណ្ឌនៃ **ន.ប.ធ.** ទាំងមូល, **ន.ប.ធ.** បានកំណត់យកផែនការសកម្មភាពបីឆ្នាំរំកិល ២០២៤-២០២៦ របស់និយ័តករបរធនបាលកិច្ច។ សម្រាប់ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំចំនួន ៣, សេចក្តីណែនាំចំនួន ៤ និងផែនការចំនួន ១។

១. គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការដាក់ឱ្យចូលនិវត្តន៍ របស់មន្ត្រីរាជការនៃនិយ័តករបរធនបាលកិច្ច

២. គោលការណ៍ណែនាំស្តីពីការពង្រឹងសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ ការប្រើប្រាស់ផ្ទៃក្នុងរបស់និយ័តករបរធនបាលកិច្ច

៣. សេចក្តីណែនាំស្តីពីការស្នើសុំប្រើប្រាស់បន្ទប់ប្រជុំ របស់និយ័តករបរធនបាលកិច្ច

៤. សេចក្តីណែនាំស្តីពីយន្តការ និងនីតិវិធីនៃការសុំច្បាប់ឈប់សម្រាកសម្រាប់មន្ត្រី នៃនិយ័តករបរធនបាលកិច្ច នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៥. សេចក្តីណែនាំស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីនៃនិយ័តករបរធនបាលកិច្ច នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៦. សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីផ្ទៃក្នុងសម្រាប់អនុវត្ត កិច្ចការគ្រប់គ្រងឯកសារចេញ-ចូល របស់និយ័តករបរធនបាលកិច្ច

៧. គោលការណ៍លើកទឹកចិត្តមន្ត្រី នៃនិយ័តករបរធនបាលកិច្ច

៨. ផែនការអភិវឌ្ឍន៍ធនធានមនុស្ស នៃនិយ័តករបរធនបាលកិច្ច

## ៤.២. ការបង្កើតកិច្ចសហប្រតិបត្តិការ

**ន.ម.ធ.** បានបន្តពង្រីកទំនាក់ទំនងជាមួយក្រសួងស្ថាប័នផ្សេងៗ ដើម្បីសម្របសម្រួល ការងាររបស់ខ្លួន ក្នុងនោះរួមមានស្ថាប័នរដ្ឋ និងវិស័យឯកជនតាមរយៈការចុះអនុស្សារណៈយោគយល់គ្នា (MOU) ក្នុងភាពជាដៃគូជាមួយនិយ័តករ ដៃគូអភិវឌ្ឍន៍វិស័យឯកជន និងបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូតាមរយៈ ការបង្កើតវគ្គបណ្តុះបណ្តាលឬកម្មវិធីកសាងសមត្ថភាពមន្ត្រី/ផ្លាស់ប្តូរបទពិសោធន៍នៅក្នុងឬក្រៅប្រទេសផងដែរ។ ក្នុងឆ្នាំ២០២៤ នេះ **ន.ម.ធ.** បានចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយវិស័យឯកជន **ចំនួន ៣** រួមមាន៖ **១-** ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក, **២-** ក្រុមហ៊ុន អាយជី គ្រុប និង **៣-** ក្រុមហ៊ុន ប៉ូមា មេឌា ឯ.ក។

ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក
STRONGHOLD TRUSTEE Co., Ltd

និយ័តករបរធនបាលកិច្ច និងក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក.
បានចុះអនុស្សរណៈនៃការយោគយល់គ្នា
កាលថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

និយ័តករបរធនបាលកិច្ច និងក្រុមហ៊ុន អាយជី ធិច គ្រុប
បានចុះអនុស្សរណៈនៃការយោគយល់គ្នា
កាលថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

IG TECH GROUP

POMA
Out-Of-Home Advertising Specialist

និយ័តករបរធនបាលកិច្ច និងក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក
បានចុះអនុស្សរណៈនៃការយោគយល់គ្នា
កាលថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤

❖ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ **ន.ម.ធ.** បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក. ស្តីពី "**ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា**" ក្នុងគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការ និងយន្តការសមស្របសម្រាប់ការផ្តល់កិច្ចសហការទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់សំដៅជំរុញការអភិវឌ្ឍបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា។




**រូបភាព៖** ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ម.ធ.** និងក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក. ស្តីពី "ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។

❖ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ **ន.ម.ធ.** បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុន អាយជី ធិច គ្រុប ស្តីពី "**ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងនវានុវត្តន៍បច្ចេកវិទ្យាគាំទ្រក្នុងវិស័យបរធនបាលកិច្ច**" ក្នុងគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការ សំដៅជំរុញនវានុវត្តន៍ប្រតិបត្តិការបរធនបាលកិច្ច តាមរយៈការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីនវានុវត្តន៍បច្ចេកវិទ្យាគាំទ្រ (Technology-enabled Innovations) និងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ។



**រូបភាព៖** ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ម.ធ.** និងក្រុមហ៊ុន អាយជី ធិច គ្រុប ស្តីពី "ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងនវានុវត្តន៍បច្ចេកវិទ្យាគាំទ្រក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤។

❖ កាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤ **ន.ប.ធ.** បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក ស្តីពី "**ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច**" ក្នុងគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការសំដៅផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច តាមរយៈយន្តការផ្សព្វផ្សាយបែបពាណិជ្ជកម្មនៅតាមទីសាធារណៈ។





**រូបភាព៖** ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ប.ធ.** និងក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក ស្តីពី "ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤។

បន្ថែមពីនេះ **ន.ប.ធ.** ក៏បានបន្តផ្តោតលើការពង្រីកបណ្តាញទំនាក់ទំនង និងការសិក្សាពីទីផ្សារក្រៅប្រទេសពីវិស័យបរធនបាលកិច្ច ក្នុងគោលបំណងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ភាពស៊ីចង្វាក់គ្នានៃក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងវិស័យបរធនបាលកិច្ច ព្រមទាំងការអនុវត្តស្របតាមស្តង់ដានវានុវត្តន៍អន្តរជាតិ។

ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដើម្បីដកស្រង់បទពិសោធន៍ ផ្លាស់ប្តូរព័ត៌មានជាមួយប្រទេសមួយចំនួនដែលមានភាពរីកចម្រើននៃវិស័យបរធនបាលកិច្ច ដូចជា៖ ប្រទេសថៃ កូរ៉េ ម៉ាឡេស៊ី និងទីក្រុងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។

❖ **កាលពីថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០២៤** ថ្នាក់ដឹកនាំ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិនៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech's Regulatory Sandbox), បច្ចេកវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិ (WealthTech), បច្ចេកវិទ្យាប្លុកឆេន (Blockchain Technology), គម្រោងបច្ចេក-វិទ្យាអនាគត, បទល្មើសបច្ចេកវិទ្យា (Digital and Cyber Fraud), ក្របខណ្ឌគតិយុត្ត និងការគ្រប់គ្រងត្រួតពិនិត្យហានិភ័យ។






**រូបភាព៖** ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិនៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ កាលពីថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០២៤។

- **កាលពីថ្ងៃទី១៥-១៧ ខែឧសភា ឆ្នាំ២០២៤** ថ្នាក់ដឹកនាំ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ។ ទស្សនកិច្ចសិក្សានេះ ក៏មានកិច្ចពិភាក្សាការងារពាក់ព័ន្ធ ជាមួយនឹងគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ (Financial Services Commission-FSC), ទីភ្នាក់ងារសេវាត្រួតពិនិត្យហិរញ្ញវត្ថុកូរ៉េ (Financial Supervisory Service-FSS), សមាគមវិនិយោគហិរញ្ញវត្ថុកូរ៉េ (Korea Financial Investment Association-KOFIA), ក្រុមហ៊ុន KB Real Estate Trust, វិទ្យាស្ថានកូរ៉េនៃឧស្សាហកម្មហិរញ្ញវត្ថុ (Korea Institute of Finance Industry-KIFI) ព្រមទាំងជាមួយនាយក និងសាស្ត្រាចារ្យនៃវិទ្យាស្ថាន KAIST (Korea Advanced Institute of Science and Technology)។




**រូបភាព៖** ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១៥-១៧ ខែឧសភា ឆ្នាំ២០២៤។

- **កាលពីថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០២៤** ថ្នាក់ដឹកនាំ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី។ ទស្សនកិច្ចសិក្សានេះ រៀបចំឡើងក្នុងគោលបំណងពិភាក្សាការងារជាមួយសមាគមបរធនបាលម៉ាឡេស៊ី ពាក់ព័ន្ធនឹងកិច្ចដំណើរការអភិវឌ្ឍន៍ទីផ្សារបរធនបាលកិច្ច ក្របខ័ណ្ឌគ្រប់គ្រងប្រតិបត្តិការ ប្រភេទផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ។




**រូបភាព៖** ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០២៤ ។

- **កាលពីថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤** ថ្នាក់ដឹកនាំ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។ ទស្សនកិច្ចសិក្សានេះ រៀបចំឡើងក្នុងគោលបំណងពិភាក្សាការងារពាក់ព័ន្ធនឹងបទពិសោធន៍អនុវត្តន៍ ក្របខ័ណ្ឌបទប្បញ្ញត្តិ បរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសម្រាប់ការវិនិយោគ កិច្ចដំណើរការនៃសមាគមបរធនបាល សមាហរណកម្មបច្ចេកវិទ្យា ការអភិវឌ្ឍទីផ្សារ ការគ្រប់គ្រងហានិភ័យ លទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការ និងការអនុវត្តប្រកបដោយនិរន្តរភាព ក៏ដូចជា ការចែករំលែកអំពីសក្តានុពល និងកាលានុវត្តភាពវិនិយោគក្នុងទីផ្សារបរធនបាលកិច្ចកម្ពុជាផងដែរ។









**រូបភាព៖** ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។

## ៤.៣. ការពង្រឹងសមត្ថភាពស្ថាប័ន

### ៤.៣.១. ការគ្រប់គ្រងធនធានមនុស្ស និងកិច្ចការរដ្ឋបាល

ដោយការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាកត្តាអាទិភាពសំខាន់មិនអាចខ្វះបានរបស់ស្ថាប័ន ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា និងផែនការសកម្មភាព និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** ព្រមទាំងដោយអនុវត្តតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាជាបន្តបន្ទាប់ រួមមានទាំងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាដើម, **ន.ប.ធ.** បានចូលរួមកសាង និងអភិវឌ្ឍធនធានមនុស្ស ដើម្បីប្រែក្លាយជាមូលធនមនុស្សដែលពោរពេញទៅដោយសមត្ថភាព និងគុណវុឌ្ឍិ ព្រមទាំងបានជ្រើសរើសមន្ត្រីបន្ថែមទៅតាមតម្រូវការចាំបាច់ ដោយផ្សារភ្ជាប់យន្តការលើកទឹកចិត្តមន្ត្រីទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលា/កម្មសិក្សាទាំងក្នុងនិងក្រៅប្រទេសដែលរៀបចំដោយក្រសួង ស្ថាប័ន និងដៃគូនានា ទាំងជំនាញរឹង និងទន់ សរុបចំនួន ១៤៩ លើក។ ក្រៅពីការចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលា/កម្មសិក្សាខាងលើ, **ន.ប.ធ.** ក៏បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន **៣ លើក** រួមមាន៖ **១-** វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី "ការឈ្វេង-យល់ពីប្រព័ន្ធ Artificial Intelligence (AI)", **២-** កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" និង **៣-** សិក្ខាសាលាស្តីពី "បច្ចេកទេសក្នុងការសរសេរអត្ថបទគតិយុត្ត"។

- **លើកទី១៖** នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤, **ន.ប.ធ.** បានរៀបចំវគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី "ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence (AI) ដែលមាន **លោកបណ្ឌិត ឡាយ គីរី** ជាវាគ្មិនកិត្តិយស ព្រមទាំងមានការអញ្ជើញចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃ **ន.ប.ធ.** មន្ត្រីតំណាងមកពីនិយ័តករ និងអង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនៅទីស្តីការ **អ.ស.ហ.**។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងដើម្បីចាប់យកនវានុវត្តន៍បច្ចេកវិទ្យា និងក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ពីដំណើរការ, របៀបប្រើប្រាស់ និងអត្ថប្រយោជន៍របស់ AI ក្នុងការជួយសម្រួលដល់ការអនុវត្តការងារប្រចាំថ្ងៃ, បង្កើនផលិតភាពការងារ, និងជាទុនចំណេះដឹងបន្ថែមក្នុងការចូលរួមចំណែកអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យានៅក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាវិស័យហិរញ្ញវត្ថុជារួម។













**រូបភាព៖** វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី “ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence (AI) កាលថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤។

➢ **លើកទី២៖** កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី **"ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា"** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងមានការចូលរួមពី **លោក អ៊ឹង សុភាល័ក្ខ** ប្រធានក្រុមហ៊ុន មេធាវី អនន្ត និង Mr. CHEN, HAN-EN នាយកប្រតិបត្តិ នៃក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក ផ្តល់ជាវាគ្មិនកិត្តិយស ព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញតំណាងពីអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងនិយ័តករ/អង្គភាពក្រោមឱវាទនៃ **អ.ស.ហ.**។ កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាពផ្ទៃក្នុងដល់មន្ត្រីនៃ **ន.ប.ធ.**។













**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤។

➢ **លើកទី៣៖** កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី "**បច្ចេកទេសក្នុងការសរសេរអត្ថបទគតិយុត្ត**" ដោយមានកិច្ចសហការជាមួយនិយ័តករមូលបត្រកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានខេមអេដ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **ឯកឧត្តម ប៊ូ ច័ន្ទភីរូ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅដើម្បីពង្រឹងសមត្ថភាពមន្ត្រីនៃនិយ័តករបរធនបាលកិច្ច, និយ័តករមូលបត្រកម្ពុជា និងនិយ័តករធានារ៉ាប់រងកម្ពុជា លើបច្ចេកទេសក្នុងការសរសេរអត្ថបទគតិយុត្ត។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជំនាញ នៃនិយ័តករទាំង ៣ និងវាគ្មិនកិត្តិយស **លោកបណ្ឌិត ព្រំម វីរៈ** ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន ខេមអេដ។










**រូបភាព៖** កម្មវិធីសិក្ខាសាលាស្តីពី "បច្ចេកទេសក្នុងការសរសេរអត្ថបទគតិយុត្ត" កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ។

បន្ថែមពីនេះ **ន.ប.ធ.** បានបន្តកសាងសមត្ថភាពមន្ត្រីជាការងារសំខាន់ ដើម្បីពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព លើការអនុវត្តការងារស្នូលរបស់ **ន.ប.ធ.** ដែលទាមទារឱ្យមានមន្ត្រីពោរពេញដោយសមត្ថភាព ទេពកោសល្យ ប្រកបដោយភាពបត់បែននៃយុគសម័យឌីជីថលនេះ, **ន.ប.ធ.** បានបញ្ជូនមន្ត្រីទៅក្រៅប្រទេសជាបន្តបន្ទាប់ដើម្បី ដកស្រង់បទពិសោធន៍ ក៏ដូចជាធ្វើទស្សនកិច្ចសិក្សាស្វែងយល់បន្ថែមពីវិស័យបរធនបាលកិច្ច។ ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលា/កម្មវិធីកសាងសមត្ថភាពនៅ តាមប្រទេសនានាដើម្បីពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងបន្ថែមពីវិស័យបរធនបាលកិច្ច រួមមាន៖ ប្រទេស ឥណ្ឌា ថៃ ហុងកុង កូរ៉េ ហ្វីលីពីន សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រទេសសិង្ហបុរី ជាដើម។



- **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំកំពូលសេដ្ឋកិច្ចពិភពលោកលើកទី៩ ស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុ៖ ការពន្លឿនបដិវត្តន៍ឌីជីថល" នៅមជ្ឈមណ្ឌលពិព័រណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក ទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា កាលពីថ្ងៃទី៨-១០ ខែសីហា ឆ្នាំ២០២៤។

- លោក លឹម ឡែត អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និងលោកស្រី ស៊ិន សុមាល័យ ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្ម បានអញ្ជើញចូលរួមកម្មវិធី "វេទិកាពិព័រណ៍ឱកាសអាជីវកម្មលើកទី១២ ឆ្នាំ២០២៤" ដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅទីស្នាក់ការកណ្តាលធនាគារ ADB ប្រទេសហ្វីលីពីន កាលពីថ្ងៃទី៩-១០ ខែតុលា ឆ្នាំ២០២៤។





❖ **លោក ចេស ចាន់ដេត** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ, **លោកស្រី ស៊ិន សុមាល័យ** ប្រធានការិយាល័យ និង**លោក ឆយ ច័ន្ទមករា** អនុប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច មានកិត្តិយសត្រូវបានចាត់ឱ្យចូលរួម "វេទិកាពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុប្រទេសសិង្ហបុរី ប្រចាំឆ្នាំ២០២៤ (Singapore FinTech Festival 2024)" នៅប្រទេសសិង្ហបុរី។

❖ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច បានចូលរួមសិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ ដែលសហការរៀបចំឡើងដោយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Group on Money Laundering- APG) និងធនាគារកណ្តាលនៃប្រទេសម៉ាឡេស៊ី ( Bank Negara Malaysia ) ស្តីពី "25th APG Typology Workshop 2024" នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី១១-១៣ ខែវិច្ឆិកា ឆ្នាំ២០២៤។







❖ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួម សន្និបាតបច្ចេកវិទ្យាហិរញ្ញវត្ថុឥណ្ឌូនេស៊ី លើកទី៦ ឆ្នាំ២០២៤ ក្រោមមូលបទ "ចំណុចរួមនៃបច្ចេកវិទ្យា៖ ការបង្កើតអនាគតនៃហិរញ្ញវត្ថុ និងលើសពីនេះ" នៅទីក្រុងហ្សាកាតា នៃប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ២០២៤។

❖ លោក ឆែម លាបហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ទិដ្ឋភាពច្បាប់នៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ-Legal Aspects of International Financial Institutions" ដែលបានរៀបចំដោយនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី២-៦ ខែធ្នូ ឆ្នាំ២០២៤។






❖ លោក ហេង សំអុល ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច, លោក តឹក សុផានុ ប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិកនៃនាយកដ្ឋានកិច្ចការទូទៅ និងកញ្ញាស៊ូស៊ិន ច័ន្ទចរិយា អនុប្រធានការិយាល័យដោះស្រាយពាក្យបណ្តឹងនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច ត្រូវបានចាត់ឱ្យចូលរួមកិច្ចប្រជុំតុមូលប្រចាំឆ្នាំស្តីពី "មូលនិធិរដ្ឋាភិបាលសកលប្រចាំឆ្នាំ លើកទី១៧ (17th Annual Global East Government Funds Roundtable" ដែលបានរៀបចំឡើងដោយស្ថាប័នវិនិយោគិន (Institutional Investor) ដែលជាស្ថាប័នផ្សព្វផ្សាយអន្តរជាតិឈានមុខគេផ្នែកធុរកិច្ច នៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី៥-៧ ខែធ្នូ ឆ្នាំ២០២៤។

បន្ថែមពីការកសាងសមត្ថភាពមន្ត្រីជាការងារអាទិភាពខាងលើ **ន.ប.ធ.** តែងតែបន្តរៀបចំកិច្ចប្រជុំផ្សេងៗ ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើសមិទ្ធផលការងាររបស់មន្ត្រីផ្ទៃក្នុង និងសមិទ្ធផលនៃ **ន.ប.ធ.** ទាំងអស់។ ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំកិច្ចប្រជុំចំនួន ៤ លើក រួមមាន៖ **លើកទី១៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤, **លើកទី២៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.**, **លើកទី៣៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** និង **លើកទី៤៖** កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារបន្ត។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤។



**រូបភាព៖** កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារបន្ត របស់ **ន.ប.ធ.** កាលពីទី២៥ ខែធ្នូ ឆ្នាំ២០២៤។

ទន្ទឹមនេះ **ន.ប.ធ.** បានអនុវត្តកិច្ចការរដ្ឋបាលទូទៅផ្សេងៗដោយជោគជ័យ ដើម្បីគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន ក៏ដូចជាធានាបាននូវនិរន្តរភាពការងារប្រចាំថ្ងៃ។ ជារួម ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានដាក់ចេញ និងសម្រេចបាននូវសមិទ្ធផលជាច្រើនតាមផែនការ ដែលមានសង្ខេបដូចខាងក្រោម៖




គិតមកត្រឹមឆ្នាំ២០២៤ នេះ **ន.ប.ធ.** មានថ្នាក់ដឹកនាំនិងមន្ត្រីសរុបចំនួន ៧០ រូប ដែលក្នុងនោះរួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈនៃ **កសហវ** ចំនួន ២០ រូប មន្ត្រីលក្ខន្តិកៈនៃ **អ.ស.ហ.** ចំនួន ៣២ រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៨ រូប។ បន្ថែមពីនេះ **ន.ប.ធ.** តែងយកចិត្តទុកដាក់ និងផ្តល់ឱកាសដល់និស្សិតដែលកំពុងបន្តការសិក្សា និង/ឬបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ ដែលមានបំណងចង់សិក្សាឈ្វេងយល់បន្ថែមពីវិស័យបរធនបាលកិច្ច ដោយបានអនុញ្ញាតឱ្យនិស្សិតចុះកម្មសិក្សាផ្ទាល់នៅ **ន.ប.ធ.** ចំនួន ១១ រូបផងដែរ។



### ៤.៣.២. ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុ ជាផ្នែកមួយដ៏សំខាន់ក្នុងការគាំទ្រដល់កិច្ចដំណើរការស្ថាប័ន ការអភិវឌ្ឍវិស័យបរធនបាលកិច្ច ក៏ដូចជាការអនុវត្តផែនការសកម្មភាព និងផែនការអភិវឌ្ឍន៍ស្ថាប័ន។ ដោយឈរលើមូលដ្ឋានច្បាប់ថវិកានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សារាចរណែនាំ និងគោលការណ៍ណែនាំនានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេសគោលការណ៍ណែនាំផ្ទៃក្នុង **ន.ប.ធ.** ពាក់ព័ន្ធនឹងការអនុវត្តថវិកា ព្រមទាំងភាពបុរេសកម្មរបស់នាយកដ្ឋានទទួលបន្ទុកនៃ **ន.ប.ធ.**, ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្ត បានបញ្ចប់ទៅទាន់ពេលស្រប តាមផែនការ ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់ទាំងក្នុងក្របខណ្ឌចូលរួមការពង្រឹងសមត្ថភាពស្ថាប័ន, ការពង្រឹងមុខងារស្ថាប័ន និងការពង្រឹងសមត្ថភាពគាំទ្រការអភិវឌ្ឍវិស័យបរធនបាលកិច្ច។

#### ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការគ្រោងថវិកា

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការគ្រោងថវិកា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២៥ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ច្បាប់ថវិកា និងសារាចរណែនាំសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២៥, ផែនការលទ្ធកម្ម, ផែនការរដ្ឋទេយ្យបុរេប្រទាន និងកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥ របស់ **ន.ប.ធ.**
- រៀបចំគម្រោងផែនការយុទ្ធសាស្ត្រថវិកា និងការគ្រោងថវិកាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២៥ ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាអាជ្ញាធរហិរញ្ញវត្ថុមិនមែនធនាគារ (សៀវភៅថវិកាឆ្នាំ២០២៥)
- រៀបចំគម្រោងផែនការសកម្មភាពដំណាក់កាលទី៤ "ថវិកាព័ត៌មានសមិទ្ធកម្ម" (CAP4) បច្ចុប្បន្នកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៥-២០២៧ និងការគ្រោងថវិកា។

#### ការកៀរគរប្រភពហិរញ្ញវត្ថុរបស់ ន.ប.ធ.

- ការគ្រប់គ្រងការប្រមូលចំណូលពីការគ្រប់គ្រងវិស័យបរធនបាលកិច្ចក្នុងប្រទេសកម្ពុជាប្រចាំឆ្នាំ២០២៤ ប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ
- ភាពជោគជ័យនៃការស្នើថវិកាក្នុងការធានាបាននូវនិរន្តរភាពផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការបើកផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.ប.ធ.** និងគាំទ្រកិច្ចដំណើរការស្ថាប័ន និងអភិវឌ្ឍវិស័យបរធនបាលកិច្ចជារួម។

#### ការគ្រប់គ្រងការអនុវត្តចំណាយរបស់ ន.ប.ធ.

- ភាពទាន់ពេល និងប្រសិទ្ធភាពក្នុងការបើកផ្តល់បៀវត្សមន្ត្រីលក្ខន្តិកៈ និងមន្ត្រីជាប់កិច្ចសន្យា និងប្រាក់ឧបត្ថម្ភជីវភាពជូនថ្នាក់ដឹកនាំ មន្ត្រីមុខងារសាធារណៈ របស់ **ន.ប.ធ.**
- ភាពទាន់ពេល និងប្រសិទ្ធភាព នៃការទូទាត់ការចំណាយរបស់ **ន.ប.ធ.**
- អនុវត្ត និងរៀបចំរបាយការណ៍កិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំរបស់ **ន.ប.ធ.** ទាន់ពេល និងមានប្រសិទ្ធភាព
- ភាពទាន់ពេលនិងប្រសិទ្ធភាពនៃការរៀបចំរបាយការណ៍នៃការអនុវត្តចំណាយប្រចាំឆ្នាំរបស់ **ន.ប.ធ.**
- ភាពទាន់ពេល និងប្រសិទ្ធភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ របស់ **ន.ប.ធ.**។

### ៤.៣.៣. ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា

**ន.ប.ធ.** បានចាត់ទុកបរិវត្តកម្មឌីជីថល ជាកត្តាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពល និងកាលានុវត្តភាពក្នុងការជំរុញសម្ទុះកំណើនវិស័យបរធនបាលកិច្ច និងការចូលរួមចំណែកសម្រេចឱ្យបាននូវការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក ព្រមទាំងជួយសម្រួលដល់នីតិវិធីការងារផ្ទៃក្នុងរបស់ **ន.ប.ធ.** ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ ដោយឈរលើមូលដ្ឋាននៃការអនុវត្តការងារតាមផែនការសកម្មភាព និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** ក៏ដូចជាការចាប់យក និងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីភាពរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល, **ន.ប.ធ.** បានដាក់ចេញ និងអនុវត្តការងារប្រកបដោយភាពជោគជ័យតាមផែនការដែលបានគ្រោងទុក។



# ការប្រកាសដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបរធនបាលកិច្ច






**ន.ប.ធ.** បានដាក់ឱ្យដំណើការនូវប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤។ ប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច មានមុខងារសម្រាប់ជួយសម្រួល និងបង្កើតផលិតភាពការងារពាក់ព័ន្ធនឹងការចុះបញ្ជី រួមមាន៖ ការបង្កើត ការចុះបញ្ជី ការពន្យារពេល ការស្នើសុំធ្វើបច្ចុប្បន្នភាព និងការបញ្ចប់បរធនបាលកិច្ច ជាដើម។

## ៤.៤. ការជំរុញ និងការអនុវត្តច្បាប់

### ៤.៤.១. ការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច

**ន.ប.ធ.** បានយកចិត្តទុកដាក់ជាសំខាន់លើ ការពង្រឹងការអនុវត្តសិទ្ធិ កាតព្វកិច្ច និងលក្ខខ័ណ្ឌតម្រូវនានារបស់បរធនបាល ដែលកំពុងគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ចរបស់បរធនបាលទាយកដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ។ ហេតុដូចនេះ ការចុះត្រួតពិនិត្យទៅលើប្រតិបត្តិការបរធនបាលកិច្ច ដោយគោរពតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន គឺជាការងារសំខាន់ដែលមន្ត្រីជំនាញនៃ **ន.ប.ធ.** ត្រូវធ្វើជាប្រចាំ ក្នុងគោលដៅតាមដាននូវរាល់សកម្មភាពគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិបរធនបាលកិច្ចរបស់បរធនបាល ដែលក្នុងនោះ រួមមាន៖ ១- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ, ២- ការរៀបចំរបាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច, ៣- ការកាន់បញ្ជិកាគណនេយ្យ, ៤- ការត្រួតពិនិត្យទីតាំងប្រតិបត្តិការបរធនបាលកិច្ច, ៥- ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា និង ៦- ការត្រួតពិនិត្យការគ្រប់គ្រងធនធានមនុស្សជាដើម ។ ក្នុងឆ្នាំ២០២៤ មន្ត្រីជំនាញ **ន.ប.ធ.** បានចុះត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ចចំនួន ២០ ករណី។

**ការចុះត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច ក្នុងឆ្នាំ ២០២៤**

| ២ លើក | ៦ លើក | ២ លើក | ២ លើក | ៦ លើក | ១ លើក | ១ លើក |
|---|---|---|---|---|---|---|
| ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល | ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃការស្នើសុំអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យបរធនបាលកិច្ច | ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល | ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃការស្នើសុំបន្តការអនុញ្ញាតក្រុមហ៊ុនបរធនបាល | ការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់បរធនបាលកិច្ច | ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃការស្នើសុំការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច | ការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃការស្នើសុំបន្តការអនុញ្ញាតប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យបរធនបាលកិច្ច |

### ៤.៤.២. ការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច

ជាការពិតណាស់ការធ្វើអធិការកិច្ចដើរតួនាទីយ៉ាងសំខាន់ដើម្បីគាំទ្រការសម្រេចបានចក្ខុវិស័យអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា ក៏ដូចជាធានាឱ្យបាននូវការធ្វើប្រតិបត្តិការទីផ្សារប្រកបដោយសណ្តាប់ធ្នាប់ របៀបរៀបរយ និងការអភិវឌ្ឍទីផ្សារ ប្រកបដោយភាពប្រកួតប្រជែង តម្លាភាព គណនេយ្យភាព និងចីរភាព។ ការធ្វើអធិការកិច្ចគឺជាយន្តការក្នុងការត្រួតពិនិត្យ តាមដាន ស្រាវជ្រាវ ស៊ើបអង្កេត និងឆែកឆេរ ករណីសង្ស័យប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ដែលបរធនបាល/ប្រតិបត្តិករបរធនបាល បានទទួលសិទ្ធិគ្រប់គ្រង ចាត់ចែង និង/ឬថែរក្សាសុវត្ថិភាពទ្រព្យសម្បត្តិបរធនបាលកិច្ចជំនួសឱ្យបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បានផ្ទេរចូលក្នុងបរធនបាលកិច្ច ដើម្បីធានានូវអនុលោមភាពច្បាប់ និងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ចំពោះបរធន-បាលកិច្ចដែលទទួលបានអាជ្ញាបណ្ណ/ការចុះបញ្ជី/ការអនុញ្ញាត/ការទទួលស្គាល់ពី **ន.ប.ធ.**។ អាស្រ័យដូចនេះ **ន.ប.ធ.** បានផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ចតាមរយៈការធ្វើអធិការកិច្ចបរធនបាលកិច្ច ដែលក្នុងឆ្នាំ២០២៤នេះ **ន.ប.ធ.** បានធ្វើអធិការកិច្ចលើក្រុមហ៊ុនចំនួន ១៣ ករណី និងការពង្រឹងការអនុវត្តច្បាប់ចំនួន ២២ ករណី។

### ៤.៤.៣. កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច

កន្លងមក **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំថ្នាក់ជាតិ និងក្រុមការងារពាក់ព័ន្ធនានា ដើម្បីសហការប្រយុទ្ធប្រឆាំងនឹងសកម្មភាពសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (AML/CFT/CPF) ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។ ដូចនេះ ដើម្បីគាំទ្រ និងអនុវត្តកិច្ចការពារវិនិយោគិននៅក្នុងវិស័យបរធនបាលកិច្ច ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលា និងបណ្តុះបណ្តាលដល់អ្នកអនុវត្តច្បាប់ ជនបង្គោលនៃបុគ្គលរាយការណ៍ និងសាធារណៈជនក្នុងសកម្មភាពប្រឆាំងការលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (AML/CFT/CPF) ដែលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាអនុលោមភាពច្បាប់ក្នុងវិស័យបរធនបាលកិច្ចបានចំនួន ៤ លើក គឺគ្រប់ផែនការមួយរយភាគរយ (១០០%)។

ជាមួយគ្នានេះ **ន.ប.ធ.** បានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចំនួនពីរ ដើម្បីគាំទ្រដល់យន្តការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច។ ជាក់ស្តែង នៅឆ្នាំ២០២៤ **ន.ប.ធ.** បានសិក្សាស្រាវជ្រាវ ព្រមទាំងរៀបចំឯកសារទស្សនទាន ចំនួន ២ គឺ៖ **១-** ឯកសារទស្សនាទានស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច, និង **២-** ឯកសារទស្សនាទានស្តីពីយន្តការ បែបបទ និងនីតិវិធីដោះស្រាយវិវាទក្នុងវិស័យបរធន-បាលកិច្ច។




បានធ្វើបទបង្ហាញស្តីពី "ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីក-សាយភាយអាវុធមហាប្រល័យ (AML/CFT/CPF) ក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី១ខែកុម្ភៈ ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលធុរកិច្ច។

**ន.ប.ធ.** បានចូលរួម និងសម្របសម្រួលអញ្ជើញក្រុមហ៊ុនបរធនបាលចូលរួមសិក្ខាសាលាស្តីពី "បទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់និយ័តករ និងបុគ្គលរាយការណ៍" កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា។



បានបន្តធ្វើបទបង្ហាញស្តីពី "ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (AML/CFT/CPF) ក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលធុរកិច្ច។

បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចរបស់បុគ្គលរាយការណ៍ និងទម្រង់របាយការណ៍បង្កកទ្រព្យសម្បត្តិ ដើម្បីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"។

ជាមួយគ្នានេះដែរ **ន.ប.ធ.** បានបង្ហាញពីការប្តេជ្ញាក្នុងការចូលរួមជាចំណែក ប្រយុទ្ធប្រឆាំងការសម្អាតសាច់ប្រាក់ តាមរយៈការចូលរួមសិក្ខាសាលា កិច្ចប្រជុំផ្សេងៗដើម្បីអភិវឌ្ឍខ្លួន តួយ៉ាង **ន.ប.ធ.** បានចូលរួមសិក្ខាសាលាគំរូប្រចាំឆ្នាំ២០២៤ ដែលសហការរៀបចំឡើងដោយ ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Group on Money Laundering- APG) និងធនាគារកណ្តាលនៃប្រទេសម៉ាឡេស៊ី (Bank Negara Malaysia) ស្តីពី "25th APG Typology Workshop 2024" នៅប្រទេសម៉ាឡេស៊ី។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងចែករំលែក ចំណេះដឹង និងបទពិសោធអំពីនិន្នាការសកលស្តីពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ពាក់ព័ន្ធនឹង (១) ការប្រើប្រាស់នីតិបុគ្គលក្នុងគោលដៅខុសច្បាប់ (Abuse of Legal Persons) និង (២) ការក្លែងបន្លំ ឬឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Cyber Enabled Fraud/Scams)។ លើសពីនេះទៀតសិក្ខាសាលានេះ មានការចូលរួមពីតំណាងស្ថាប័នហិរញ្ញវត្ថុ រដ្ឋឯកជន នៃបណ្តាប្រទេសសមាជិករបស់ APG និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងប្រព័ន្ធហិរញ្ញវត្ថុនិងការប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។






#### ៤.៤.៤. កិច្ចការនីតិកម្ម

ដើម្បីឱ្យមានសង្គតិភាពនៃការរៀបចំលិខិតគតិយុត្តរវាងក្រសួង-ស្ថាប័ន និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យបរធនបាលកិច្ច **ន.ប.ធ.** បានធ្វើការពិនិត្យ និងផ្ដល់យោបល់ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធលើការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងលិខិតគតិយុត្តផ្សេងៗ ក្នុងឆ្នាំ២០២៤ បានចំនួន ១០ ករណី។ ជាមួយគ្នានេះ ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានផ្ដល់ប្រឹក្សាយោបល់ពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ និងបច្ចេកទេសនៃប្រតិបត្តិការបរធនបាលកិច្ចជូនទៅវិស័យឯកជន ក៏ដូចជាសាធារណជន និងពិនិត្យផ្ដល់យោបល់ផ្នែកច្បាប់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន ១០ ករណី។ ក្រៅពីនេះ **ន.ប.ធ.** បានផ្ដល់សេវាប្រឹក្សាយោបល់ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចឱ្យទៅវិស័យឯកជន រួមមានការរៀបចំលិខិតបរធនបាលកិច្ចសម្រាប់ការគ្រប់គ្រង និងចាត់ចែងបរធនបរធនបាលកិច្ចដែលរៀបចំដោយបរធនបាលទាយក និងលិខិតបរធនបាលកិច្ចសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកដែលរៀបចំដោយប្រតិបត្តិករបរធនបាល ក៏ដូចជាសាធារណជន និងពិនិត្យផ្ដល់យោបល់ផ្នែកច្បាប់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច របស់ក្រសួង-ស្ថាប័ន រួមមានសេចក្ដីព្រាងច្បាប់ សេចក្ដីព្រាងអនុក្រឹត្យ សេចក្ដីព្រាងប្រកាស សេចក្ដីព្រាងគោលការណ៍ណែនាំ និងការរៀបចំ MoU សរុប ចំនួន ២៨ ករណី។

## ៤.៥. ការបណ្ដុះបណ្ដាល អប់រំ និងផ្សព្វផ្សាយ

### ៤.៥.១. ការបណ្ដុះបណ្ដាល និងអប់រំ

#### ៤.៥.១.១. កម្មវិធីបណ្ដុះបណ្ដាលនិងការប្រឡងគុណវុឌ្ឍិ និងការអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច

បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ សំដៅដល់បុគ្គលដែលផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ចដែលតម្រូវឱ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល និងប្រឡងដែលផ្ដោតជាសំខាន់ទៅលើបទប្បញ្ញត្តិ និងផ្នែកប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិក្នុងការផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ចនេះ។ បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ រួមមានក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គល និងក្រុមហ៊ុនផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច។ វគ្គបណ្ដុះបណ្ដាលគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច ត្រូវបានរៀបចំឡើងដោយមានមន្ត្រីជំនាញរបស់ **ន.ប.ធ.** ធ្វើបទបង្ហាញពីប្រធានបទពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យបរធនបាលកិច្ច។ ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានរៀបចំវគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចបានចំនួន ២លើក និងមានសិក្ខាកាម សរុបចំនួន ៣៦០ រូប។

- ការបណ្ដុះបណ្ដាលនិងការប្រឡងគុណវុឌ្ឍិ និងការអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៤ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២០ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ដែលមានសិក្ខាកាម សរុបចំនួន ១៦២ រូប។
- ការបណ្ដុះបណ្ដាលនិងការប្រឡងគុណវុឌ្ឍិ និងការអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៥ បានប្រព្រឹត្តទៅកាលពីថ្ងៃទី១-៤ ខែកក្កដា ឆ្នាំ២០២៤ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ដែលមានសិក្ខាកាម សរុបចំនួន ១៩៨ រូប។

**លើកទី៤**



សិក្ខាកាម **១៦២** រូប

**លើកទី៥**



សិក្ខាកាម **១៩៨** រូប



















**រូបភាព៖** ការបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិ និងការអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៤ និងលើកទី៥។

### ៤.៥.១.២.ការបញ្ជ្រាបការយល់ដឹងជាសាធារណៈ

ដើម្បីជំរុញដល់ការយល់ដឹងពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច **ន.ម.ធ.** ផ្តោតជាសំខាន់លើការបណ្តុះ-បណ្តាលដល់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ដូចខាងក្រោម៖

- ការអប់រំវិនិយោគិន សមាគមធុរកិច្ចជាតិ និងអន្តរជាតិនៅកម្ពុជា អ្នកសារព័ត៌មាន និងសាធារណជន ព្រមទាំងស្ថាប័នរដ្ឋ/ឯកជន ធនាគារ ឬគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ និងបុគ្គលពាក់ព័ន្ធដទៃទៀតដល់ទីកន្លែង និង/ឬតាមប្រព័ន្ធអនឡាញ។
- ការបណ្តុះបណ្តាលដល់ក្រុមហ៊ុនបរធនបាល និងបុគ្គលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។
- វេទិកា និង/ឬសន្និសីទស្តីពីវឌ្ឍនភាព បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ច ដែលកម្មវិធីនេះនឹងបើកឱកាសឱ្យសាធារណជន ក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធនានាទទួលបានព័ត៌មាន និងចំណេះដឹងបន្ថែមស្តីពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច។

### ក. ការបញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិករតាមបណ្តាខេត្តនានា

ដើម្បីផ្សព្វផ្សាយអំពីតួនាទី និងសារសំខាន់របស់យន្តការបរធនបាលកិច្ច ក្នុងការបង្កើត និងបង្កើនទំនុកចិត្ត ក៏ដូចជាទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានា ក្នុងកម្រិតពាក់ព័ន្ធណាមួយតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមាន **ន.ម.ធ.** បានសហការជាមួយរដ្ឋបាលខេត្តចំនួន ៦ រួមមាន៖ ខេត្តកែប ក្រចេះ កំពង់ចាម កំពត បាត់ដំបង និងខេត្តសៀមរាប។






## ខេត្តសៀមរាប

- ❖ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤
- ❖ កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ម.ធ.** កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤
- ❖ កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារបន្ត របស់ **ន.ម.ធ.** កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤
- ❖ កិច្ចការការងារសង្គម នៅមណ្ឌលកុមារកំព្រាខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។



## ខេត្តកំពង់ចាម

- ❖ កម្មវិធីសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤។



## ខេត្តកែប

- ❖ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤។



## ខេត្តបាត់ដំបង

- ❖ កម្មវិធីសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤។



## ខេត្តកំពត

- ❖ កម្មវិធីសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។




## ខេត្តក្រចេះ

- ❖ កម្មវិធីសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤
- ❖ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤។

## ខ. ការបញ្ជ្រាបការយល់ដឹងដល់សមាគមធុរកិច្ច និងវិនិយោគិន

**ន.ប.ធ.** បានចាត់ទុកការបញ្ជ្រាបការយល់ដឹងដល់សមាគមធុរកិច្ច វិនិយោគិន ធនាគារ និងធុរជនសក្តានុពល ជាការបញ្ជ្រាបការយល់ដឹង និងផ្សព្វផ្សាយព័ត៌មានពីវិស័យបរធនបាលកិច្ច ជាកិច្ចការងារអាទិភាព។ ក្នុងន័យនេះ **ន.ប.ធ.** បានសហការជាមួយសមាគមធុរកិច្ចក្នុង និងក្រៅប្រទេស ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះ-បណ្តាល ដែលផ្តោតសំខាន់លើគុណប្រយោជន៍នៃបរធនបាលកិច្ចដែលជាយន្តការដ៏មានប្រសិទ្ធភាព និងប្រកបដោយទំនុកចិត្តសម្រាប់ការវិនិយោគលើអចលនទ្រព្យ និងអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់ធុរកិច្ច។ ក្នុងឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំកម្មវិធីកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ចំនួន ១៧ លើក ដល់សមាគមធុរកិច្ច វិនិយោគិន ធនាគារ និងធុរជនសក្តានុពល នៅប្រទេសកម្ពុជា ដូចជា៖ សមាគមអ្នកកិវឌ្ឍន៍លំនៅឋានកម្ពុជា (HDAC), ធនាគារ ស្ថាបនា ភីអិលស៊ី, ធនាគារ អេស៊ីលីដា ភីអិលស៊ី, ធនាគារ វីង (ខេមបូឌា) ម.ក, ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី, ក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក, ធនាគារ សហពាណិជ្ជ ក.អ និងធនាគារ អូរៀនថល ម.ក ជាដើម។

- កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី "**បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត**" សម្រាប់សមាជិក-សមាជិកានៃសមាគម CVEA ដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងវិសាលភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ចដល់សមាគម CVEA ដែលជាតួអង្គពាក់ព័ន្ធដ៏សំខាន់ក្នុងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា និងដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់ធុរកិច្ចរបស់ខ្លួន នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤។







***រូបភាព៖*** *កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី "បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត" កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤។*

- កម្មវិធីបណ្តុះបណ្តាលស្តីពី "**យន្តការបរធនបាលកិច្ចនៅកម្ពុជា**" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ ស្ថាបនា ភីអិលស៊ី ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច នៅទីស្នាក់ការ ធនាគារ ស្ថាបនា ភីអិលស៊ី កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។




**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។

- កម្មវិធីបណ្តុះបណ្តាលស្តីពី **"យន្តការបរធនបាលកិច្ចនៅកម្ពុជា"** សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារទទួលបានការអនុញ្ញាតពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាល ផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច នៅទីស្នាក់ការ ធនាគារ អេស៊ីលីដា ភីអិលស៊ី កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤។




**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤។

- កម្មវិធីបណ្តុះបណ្តាលស្តីពី **"យន្តការបរធនបាលកិច្ចនៅកម្ពុជា"** សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច នៅទីស្នាក់ការ ធនាគារ វីង (ខេមបូឌា) ម.ក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤។




**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤។

❖ កម្មវិធីបណ្តុះបណ្តាលស្តីពី **"យន្តការបរធនបាលកិច្ចនៅកម្ពុជា"** សម្រាប់ថ្នាក់ដឹកនាំ បុគ្គលិក និងអតិថិជន របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាក្រុមហ៊ុនបរធនបាលធ្វើប្រតិបត្តិការគ្រប់គ្រង, ចាត់ចែង និងប្រតិបត្តិការរក្សាសុវត្ថិភាព ឬរក្សាទុក សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម នៅសណ្ឋាគារ សុខា ភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤។





**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤។

❖ កម្មវិធីបណ្តុះបណ្តាលស្តីពី **"យន្តការបរធនបាលកិច្ចនៅកម្ពុជា"** សម្រាប់ថ្នាក់ដឹកនាំ, បុគ្គលិក និងក្រុមហ៊ុនជាដៃគូរបស់ក្រុមហ៊ុន ស្រ្តូងហ្វូល ត្រាសធី ឯ.ក ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមអំពីយន្តការបរធនបាលកិច្ចអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅកម្ពុជា ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកមកពីក្រុមហ៊ុន ស្រ្តូងហ្វូល ត្រាសធី ឯ.ក ដែលជាក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបុគ្គល ក៏ដូចជាក្រុមហ៊ុនដៃគូរបស់ក្រុមហ៊ុន ស្រ្តូងហ្វូល ត្រាសធី ឯ.ក ផងដែរ នៅអគារ Morgan Tower នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤។





**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤។

❖ កម្មវិធីបាឋកថារបស់ **ឯកឧត្តម ហួត ពុំ** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាទីប្រឹក្សាផ្ទាល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមប្រធានបទស្តីពី៖ “**បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា**” នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤។







**រូបភាព៖** កម្មវិធីបាឋកថារបស់ **ឯកឧត្តម ហួត ពុំ** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤។

❖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី “**បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់ការវិនិយោគ**” ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយសមាគមស្បែកជើងកម្ពុជា សមាគមផលិតផលធ្វើដំណើរ និងស្បែកនៅកម្ពុជា និងសភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំនៅកម្ពុជា (MBCC)។ កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែទូលំទូលាយពីកាលានុវត្តភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ច ព្រមទាំងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចពីថ្នាក់ដឹកនាំ និងសមាជិក-សមាជិកានៃសមាគមស្បែកជើងកម្ពុជា សមាគមផលិតផលធ្វើដំណើរ និងស្បែកនៅកម្ពុជា និង MBCC ដែលជាវិនិយោគិន និងធុរជនសក្តានុពលនៅកម្ពុជា ដើម្បីអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចរបស់ខ្លួន នៅអគារ Morgan Tower នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤។










**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រេកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់ការវិនិយោគ" កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤។

- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី **"វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"** ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយរដ្ឋបាលខេត្តសៀមរាប។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀតពីវិស័យបរធនបាលកិច្ចនៅកម្ពុជា ទៅដល់ថ្នាក់ដឹកនាំ និងតំណាង មកពីស្ថាប័នមន្ទីរ-អង្គភាពនានានៃរដ្ឋបាលខេត្តសៀមរាប, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងមកពីក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** នៅសណ្ឋាគារ អេមព្រីស អង្គរ រីសត និងស្ប៉ា ខេត្តសៀមរាប នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។






**រូបភាព៖** កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។

❖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី **"បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស"** ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុន អេស អ៊ីម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឹមេន ឯ.ក។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីយល់ដឹងឱ្យបានកាន់តែទូលំទូលាយពីកាលានុវត្តភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ច ព្រមទាំងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចរបស់ថ្នាក់ដឹកនាំ និងបុគ្គលិក នៃក្រុមហ៊ុន អេស អ៊ីម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឹមេន ឯ.ក និងសហគមន៍កូរ៉េនៅកម្ពុជា ដែលជាវិនិយោគិន និងធុរជនសក្តានុពលនៅកម្ពុជា ដើម្បីអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចរបស់ខ្លួន នៅសណ្ឋាគារ ភ្នំពេញ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤។







**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស" កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤។

❖ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី **"វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"** ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយរដ្ឋបាលខេត្តក្រចេះ។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀតពីវិស័យបរធនបាលកិច្ច ទៅដល់ថ្នាក់ដឹកនាំ និងតំណាងមកពីមន្ទីរ-អង្គភាពចំណុះរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទនៅខេត្តក្រចេះ, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងមកពីក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤។





**រូបភាព៖** កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤។

❖ កិច្ចប្រជុំស្តីពី "**ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច**" នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤។




**រូបភាព៖** កិច្ចប្រជុំស្តីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបរធនបាលកិច្ច" នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤។

❖ វគ្គបណ្តុះបណ្តាលស្តីពី "**យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា**" ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយធនាគារ សហពាណិជ្ជ ក.អ សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកជំនាញទទួលបន្ទុក និងបុគ្គលិកពាក់ព័ន្ធរបស់ធនាគារ សហពាណិជ្ជ ក.អ ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុកក្នុងវិស័យបរធនបាលកិច្ច នៅទីស្នាក់ការកណ្តាលរបស់ធនាគារ សហពាណិជ្ជ ក.អ នៅរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤។




**រូបភាព៖** វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា" នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤។

❖ កម្មវិធីបណ្តុះបណ្តាលស្តីពី "**យន្តការបរធនបាលកិច្ចនៅកម្ពុជា**" ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយធនាគារ អូរៀនថល ម.ក សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ អូរៀនថល ម.ក ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម នៅទីស្នាក់ការកណ្តាលរបស់ធនាគារ អូរៀនថល ម.ក នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤។





**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤។

❖ សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី **"វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"** ក្រោមកិច្ចសហការរវាង **ន.ប.ធ.** ជាមួយរដ្ឋបាលខេត្តកែប។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀតពីវិស័យបរធនបាលកិច្ចនៅកម្ពុជា ទៅដល់ថ្នាក់ដឹកនាំ និងតំណាងមកពីមន្ទីរ-អង្គភាពចំណុះរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទនៅខេត្តកែប, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងមកពីក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤។




**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤។

## គ. សិក្ខាសាលាបញ្ជ្រាបការយល់ដឹងដល់និស្សិតនៅសាកលវិទ្យាល័យ

បន្ថែមពីការរៀបចំកម្មវិធីសិក្ខាសាលាបញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិករ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច **ន.ប.ធ.** ក៏បានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងជាសាធារណៈសម្រាប់និស្សិតនៅសាកលវិទ្យាល័យតាមបណ្ដាខេត្ត-រាជធានី ចំនួន ១២ លើក ផងដែរ ដើម្បីផ្ដល់ឱកាសឱ្យនិស្សិតបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច និងកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

- សិក្ខាសាលាស្ដីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច ។




**រូបភាព៖** សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។

- សិក្ខាសាលាស្ដីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅសាកលវិទ្យាល័យជាតិជាស៊ីម កំចាយមារ សាខាខេត្តកំពង់ចាម កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យជាតិជាស៊ីម កំចាយមារ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យជាតិជាស៊ីម កំចាយមារ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី "**ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា**" នៅសាកលវិទ្យាល័យកម្ពុជា កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យសាកលវិទ្យាល័យកម្ពុជា អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធន-បាលកិច្ច ។




**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យកម្ពុជា កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី "**ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច**" នៅសាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីមន្ត្រីមធ្យមអំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីមន្ត្រីមធ្យម ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។




**រូបភាព៖** សិក្ខាសាលាស្តីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" នៅសាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្ដីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ។





**រូបភាព៖** សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្ដីពី **"ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"** ដោយបានសហការជាមួយរាជបណ្ឌិតសភាកម្ពុជា កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិត អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា។





**រូបភាព៖** សិក្ខាសាលាស្ដីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" នៅរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅសាកលវិទ្យាល័យន័រតុន កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យន័រតុន កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី **"ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅសាកលវិទ្យាល័យឯកទេស នៃកម្ពុជា កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្ដីពី "ការស្វែងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យឯកទេស នៃកម្ពុជា កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។

- សិក្ខាសាលាស្ដីពី **"ការស្វែងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"** នៅសាកលវិទ្យាល័យក្រចេះ នៅខេត្តក្រចេះ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្ដីពី "ការស្វែងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៅសាកលវិទ្យាល័យក្រចេះ នៅខេត្តក្រចេះ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤។

- សិក្ខាសាលាស្ដីពី **"ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"** ដោយបានសហការជាមួយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។




**រូបភាព៖** សិក្ខាសាលាស្ដីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤។

❖ សិក្ខាសាលាស្តីពី "**ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច**" ដោយបានសហការជាមួយបណ្ឌិត្យសភាតូមិន្ទយុត្តិធម៌កម្ពុជា កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិត អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច ព្រមទាំងផ្តល់ឱកាសដល់សិស្សថៅក្រមសិស្សព្រះរាជអាជ្ញា និងសិស្សសារការី ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។




**រូបភាព៖** សិក្ខាសាលាស្តីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" នៅបណ្ឌិត្យសភាតូមិន្ទយុត្តិធម៌កម្ពុជា កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤។

## ឃ. សិក្ខាសាលាផ្សព្វផ្សាយ និងការដាក់ឱ្យអនុវត្តយន្តការនានា

**ន.ប.ធ.** បានរៀបចំនូវសិក្ខាសាលាផ្សព្វផ្សាយនានា ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ជាពិសេសភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច អំពីការអនុវត្តយន្តការនានាក្នុងវិស័យបរធនបាលកិច្ចប្រកបដោយភាពត្រឹមត្រូវ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានដាក់ឱ្យអនុវត្ត និងរៀបចំនូវសិក្ខាសាលាផ្សព្វផ្សាយនូវយន្តការ ចំនួន ៧ រួមមាន៖ **១-** សិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល", **២-** សិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច", **៣-** សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ **ន.ប.ធ.** ជាផ្លូវការ, **៤-** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពី ទម្រង់របាយការណ៍របស់បរធនបាល", **៥-** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច", **៦-** សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" និង **៧-** សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"។





❖ កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ជាពិសេសបរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** អំពីការអនុវត្តនូវកាតព្វកិច្ចផ្ដល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាតរបស់បរធនបាលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច នៅក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងដើម្បីធានាឱ្យបាននូវការបំពេញកាតព្វកិច្ច និងការធ្វើប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាលប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។





❖ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច" ដើម្បីផ្សព្វផ្សាយអំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្មរបស់ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដល់សាធារណជន, បរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ជាពិសេសក្រុមហ៊ុនផ្ដល់សេវាសវនកម្ម ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបំណងដាក់ពាក្យស្នើសុំការទទួលស្គាល់ពី **ន.ប.ធ.** ក្នុងការផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាឱ្យបាននូវគុណភាពសវនកម្ម និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។




❖ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ការដាក់ឱ្យអនុវត្តគេហទំព័រ (Website) របស់ **ន.ប.ធ.** ជាផ្លូវការ" ដើម្បីធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយបន្ថែមទៀតនូវ Website របស់ **ន.ប.ធ.** ទៅដល់និយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.**, តួអង្គនិងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន ដែលសំដៅដល់ការដាក់ឱ្យអនុវត្តប្រកបដោយសណ្ដាប់ធ្នាប់ តម្លាភាព និងទំនុកចិត្ត ក៏ដូចជាការផ្ដល់នូវភាពងាយស្រួលដល់អ្នកចូលមើល (Visitor) ក្នុងការទាញយកនូវរាល់ឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ជាដើម។




❖ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្ដីពី ទម្រង់របាយការណ៍របស់បរធនបាល" ដើម្បីបញ្ជ្រាបការយល់ដឹងដល់បរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** ក្នុងការបំពេញកាតព្វកិច្ចផ្ដល់របាយការណ៍របស់បរធនបាល សំដៅដល់ការអនុវត្តប្រកបដោយសង្គតិភាព សណ្ដាប់ធ្នាប់ និងប្រសិទ្ធភាព។







- កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" ដើម្បីផ្សព្វផ្សាយពីទិដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech) និងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច (FinTech's Regulatory Sandbox in the Trust Sector) ក៏ដូចជាគោលការណ៍ណែនាំស្ដីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" (Guideline on FinTech's Regulatory Sandbox in the Trust Sector) ដែលបានដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ កន្លងទៅ។







- កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច" ដើម្បីផ្សព្វផ្សាយអំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដល់សាធារណជន, បរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ជាពិសេសក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបំណងដាក់ពាក្យស្នើសុំការទទួលស្គាល់ពី **ន.ប.ធ.** ក្នុងការផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាឱ្យបាននូវគុណភាពសវនកម្ម និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។







- កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងប្រកាសស្ដីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល" ក្នុងគោលបំណងទទួលបានមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ជាពិសេសអ្នកអនុវត្តការងារផ្ទាល់ ដើម្បីឱ្យសេចក្ដីព្រាងប្រកាសនេះ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយសំដៅដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច។

### ៤.៥.២. ការផ្សព្វផ្សាយ

#### ៤.៥.២.១. ការរៀបចំរបាយការណ៍ និងបោះពុម្ព

ដើម្បីជាយន្តការបញ្ជ្រាបការយល់ដឹងដល់សាធារណជនឱ្យកាន់តែទូលំទូលាយពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសភាគីពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច **ន.ប.ធ.** បានរៀបចំចងក្រង និងបោះពុម្ពនូវផែនការសកម្មភាព ព្រឹត្តិបត្រព័ត៌មាន របាយការណ៍សមិទ្ធផលនានា ព្រមទាំងរៀបចំនូវកម្រងបទដ្ឋានគតិយុត្តិសំខាន់ៗក្នុងវិស័យបរធនបាលកិច្ច សម្រាប់ផ្សព្វផ្សាយដល់សាធារណជនតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ **ន.ប.ធ.**។

**ក. ការរៀបចំ និងបោះពុម្ពរបាយការណ៍សមិទ្ធផលការងារ ឆ្នាំ ២០២១-២០២៣ របស់ ន.ប.ធ.**

របាយការណ៍សមិទ្ធផលការងារ ឆ្នាំ ២០២១-២០២៣ របស់ **ន.ប.ធ.** បានទទួលហត្ថលេខាអនុញ្ញាតពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ និងបានផ្សព្វផ្សាយជាផ្លូវការ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤។ របាយការណ៍នេះ រៀបចំឡើងដើម្បីប្រមូលនិងចងក្រងនូវសមិទ្ធផលសំខាន់ៗដែល **ន.ប.ធ.** សម្រេចបានក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ របាយការណ៍នេះ បានចែកចេញជា ៣ ផ្នែក សំខាន់ៗ រួមមាន៖ **១- ផ្នែកទី១៖** អំពីនិយ័តករបរធនបាលកិច្ច, **២- ផ្នែកទី២៖** សមិទ្ធផលសំខាន់ៗរបស់និយ័តករបរធនបាលកិច្ច និង **៣- ផ្នែកទី៣៖** ឧបសម្ព័ន្ធ។ របាយការណ៍នេះ បានផ្តល់នូវអត្ថប្រយោជន៍ដល់សិស្ស-និស្សិត អ្នកស្រាវជ្រាវ វិនិយោគិន និងសាធារណជន អាចប្រើប្រាស់សមិទ្ធផលទាំងនេះជាមូលដ្ឋាននៃស្ថានភាពទីផ្សារបរធនបាលកិច្ចនៅកម្ពុជា។




សូមស្កេន QR Code ដើម្បីទាញយករបាយការណ៍សមិទ្ធផលការងារ ឆ្នាំ ២០២១-២០២៣ របស់និយ័តករបរធនបាលកិច្ច

## ខ. ការរៀបចំ និងបោះពុម្ពព្រឹត្តិបត្រព័ត៌មានផ្សព្វផ្សាយ

ដើម្បីបន្តចងក្រងនិងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍ និងសកម្មភាពនានា ដែល **ន.ប.ធ.** បានធ្វើដើម្បីអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនក្នុងនាមជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ព្រឹត្តិបត្រព័ត៌មានប្រចាំខែ ត្រូវបានរៀបចំឡើងនិងចុះផ្សាយជាសាធារណៈយ៉ាងទៀងទាត់ គិតចាប់ពីខែសីហា ឆ្នាំ២០២២ មក។ គិតត្រឹមឆ្នាំ២០២៤ **ន.ប.ធ.** បានរៀបចំ និងចងក្រងព្រឹត្តិបត្រព័ត៌មានប្រចាំខែចំនួន ៤៣ លេខ។




សូមស្កេន QR Code ដើម្បីទាញយកព្រឹត្តិបត្រព័ត៌មានប្រចាំខែ ឆ្នាំ២០២៤
(ជាភាសាខ្មែរ)




សូមស្កេន QR Code ដើម្បីទាញយកព្រឹត្តិបត្រព័ត៌មានប្រចាំខែ ឆ្នាំ២០២៤
(ជាភាសាអង់គ្លេស)

### គ. ការរៀបចំ និងបោះពុម្ពផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច

ផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច ទទួលបានហត្ថលេខាអនុញ្ញាតពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដាក់ឱ្យអនុវត្ត កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤។ ផែនការអភិវឌ្ឍន៍នេះ បានកំណត់ច្បាស់លាស់អំពីចក្ខុវិស័យ គោលបំណង គោលដៅ មុខងារ និងបេសកកម្មរបស់ស្ថាប័ន ដើម្បីពង្រឹងនិងអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការគាំទ្រដល់ការអភិវឌ្ឍវិស័យ។ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រដែលដាក់ចេញ និងការដ្ឋានការងារសំខាន់ៗ ចំនួន បី ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពការងារចំនួន បួន ដូចខាងក្រោម៖

**ចង្កោមសកម្មភាពទី១**
**គាំទ្រ សម្របសម្រួល និងគ្រប់គ្រងកិច្ចការទូទៅ**

**ចង្កោមសកម្មភាពទី១** មានសូចនាករចម្បងៗចំនួន បី រួមមាន៖ ១- ការគ្រប់គ្រង តាមដាន និងអនុវត្តការចំណាយកញ្ចប់ថវិការបស់ **ន.ប.ធ.** ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព, ២- ការផ្គត់ផ្គង់ ថែទាំ វាយតម្លៃ អភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យារបស់ **ន.ប.ធ.** និង ៣- សេវាគាំទ្រការងាររដ្ឋបាលរបស់ **ន.ប.ធ.** និងការរៀបចំបើកប្រាក់បៀវត្សជូនមន្ត្រី។

**ចង្កោមសកម្មភាពទី២**
**ស្រាវជ្រាវ បណ្តុះបណ្តាល និងបង្កើតកិច្ចសហប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច**

**ចង្កោមសកម្មភាពទី២** មានសូចនាករចម្បងៗចំនួន បី រួមមាន៖ ១- ស្រាវជ្រាវ អភិវឌ្ឍន៍ទីផ្សារ និងរៀបចំគម្រោងផែនការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច, ២- លើកកម្ពស់ចំណេះដឹងជាសាធារណៈស្តីពីវិស័យបរធនបាលកិច្ច និង ៣- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ។

**ចង្កោមសកម្មភាពទី៣**
**គ្រប់គ្រង ត្រួតពិនិត្យ និងតាមដានការចុះបញ្ជីបរធនបាលកិច្ច ប្រតិបត្តិករបរធនបាល និងបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច**

**ចង្កោមសកម្មភាពទី៣** មានសូចនាករចម្បងៗចំនួន បី រួមមាន៖ ១- រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច, ២- គ្រប់គ្រង ត្រួតពិនិត្យ និងតាមដានការចុះបញ្ជីបរធនបាលកិច្ច និងបរធនបាល/បុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច និង ៣- ចុះត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការបរធនបាលកិច្ច/បរធនបាល។

**ចង្កោមសកម្មភាពទី៤**
**ការជំរុញ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច**

**ចង្កោមសកម្មភាពទី៤** មានសូចនាករចម្បងៗចំនួន បី រួមមាន៖ ១- ធ្វើអធិការកិច្ច ដើម្បីជំរុញនិងពង្រឹងការអនុវត្តច្បាប់ និងអនុវត្តតាមដានសកម្មភាពទាក់ទងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងវិស័យបរធនបាលកិច្ច, ២- កិច្ចការពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច និង ៣- កិច្ចការនីតិកម្ម។




ផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០)
របស់និយ័តករបរធនបាលកិច្ច

### ឃ. ការរៀបចំ និងបោះពុម្ពផែនការសកម្មភាពបីឆ្នាំរំកិល ២០២៤-២០២៦ របស់ ន.ប.ធ.

ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៤-២០២៦ របស់និយ័តករបរធនបាលកិច្ច ទទួលបានហត្ថលេខាអនុញ្ញាតពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដាក់ឱ្យអនុវត្ត កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤។ ផែនការសកម្មភាពនេះ បានកំណត់លម្អិតអំពីកម្មវិធីការងារដែលត្រូវអនុវត្តប្រចាំឆ្នាំ (ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៦) និងបានរៀបចំសកម្មភាពការងារដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤។




ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៤-២០២៦
របស់និយ័តករបរធនបាលកិច្ច

### ៤.៥.២.២. ការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ

នៅក្នុងឆ្នាំ២០២៤ នេះ **ន.ប.ធ.** បានដាក់ចេញ និងបន្តគិតគូរអភិវឌ្ឍនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គមផ្លូវការមួយចំនួន សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ **ន.ប.ធ.** ក៏ដូចជាដើម្បីឆ្លើយតបតាមផែនការសកម្មភាព សូចនាករ និងពេលវេលាដែលបានកំណត់ ទាំងក្នុងក្របខ័ណ្ឌតាមផែនការ និងក្នុងក្របខ័ណ្ឌក្រៅផែនការ **ន.ប.ធ.**។



"គេហទំព័រហ្វេសប៊ុក (Facebook Page)"

https://www.facebook.com/trustregulatorcambodia



"និយ័តករបរធនបាលកិច្ច (ន.ប.ធ.)" ឬ "Trust Regulator (TR)"

https://www.trustregulator.gov.kh



"ឆានែលតេឡេក្រាម (Telegram Channel)"

https://t.me/trustregulator




"តីកតុក (TikTok)"

https://www.tiktok.com/@trust_regulator?




"ឆានែលយូធូប (YouTube Channel)"

https://www.youtube.com/@trustregulatorca

## ៤.៦. សមិទ្ធផលផ្សេងៗ

### ៤.៦.១. ការអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម

ក្រៅពីការអនុវត្តតួនាទី និងភារកិច្ចជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ច **ន.ប.ធ.** ត្រូវបានប្រគល់ភារកិច្ចជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គម្រោង ACSEP ជាគម្រោងរបស់រាជរដ្ឋាភិបាល និងទទួលបានកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) យោងតាមកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយ ADB ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០។

គម្រោង ACSEP នឹងចូលរួមចំណែកក្នុងការពង្រឹងខ្សែច្រវាក់តម្លៃ នៃផលិតផលកសិកម្មដែលមានលក្ខណៈប្រកួតប្រជែងមួយចំនួន រួមមាន៖ ដំឡូងមី ផ្លែស្វាយ ស្វាយចន្ទី បន្លែ និងមាន់ស្រុក ក្នុងខេត្តគោលដៅចំនួន ៦ គឺខេត្តកំពង់ចាម កំពង់ធំ ត្បូងឃ្មុំ សៀមរាប ព្រះវិហារ និងខេត្តឧត្តរមានជ័យ ព្រមទាំងផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍កសិកម្មចំនួន ២៣០ (ប្រហែល ២៧,០០០ គ្រួសារ) និងកសិ-ធុរកិច្ច ចំនួន ៥០ នៅក្នុងតំបន់គោលដៅគម្រោង។

### គោលដៅធំៗ ចំនួន ៣ នៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម

**១** ជួយសម្រួលដល់ការទទួលបានឥណទានសម្រាប់សហគ្រាសកសិ-ធុរកិច្ច សហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់ស្រុក ដែលអនុវត្តដោយនិយ័តករបរធនបាលកិច្ចក្រោមក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**២** ជួយលើកកម្ពស់ទំនាក់ទំនងទីផ្សារក្នុងចំណោមសហគ្រាសកសិ-ធុរកិច្ច និងសហគមន៍កសិកម្ម និងលើកកម្ពស់សុវត្ថិភាព និងគុណភាពម្ហូបអាហារ ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**៣** ធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់បណ្តាញផ្លូវដឹកជញ្ជូនពីកសិដ្ឋានផលិត ទៅកាន់ទីផ្សារដែលអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ។

នៅក្នុងការអនុវត្តគោលដៅទី១ ដើម្បីជួយសម្រួលដល់ការទទួលបានឥណទាន សម្រាប់សហគ្រាសកសិ-ធុរកិច្ច សហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់ស្រុកតាមរយៈគម្រោង ACSEP ពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និងធនាគារស្ថាបនា (SPNB) ត្រូវបានជ្រើសរើសជាស្ថាប័នហិរញ្ញវត្ថុដៃគូ យោងតាមកិច្ចព្រមព្រៀងកម្ចីឧបត្ថម្ភធន (Subsidiary Loan Agreement, SLA) រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារទាំងពីរ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។

គិតត្រឹមឆ្នាំ២០២៤ នេះ ស្ថាប័នហិរញ្ញវត្ថុដៃគូរទាំងពីរទទួលបានឥណទានពីគម្រោង សរុបចំនួន **៦.៦២៨.៦៨០,២៦ ដុល្លារអាមេរិក** ក្នុងនោះធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ទទួលបានឥណទានចំនួន **២.៦១១.០០០ ដុល្លារអាមេរិក** និងធនាគារ ស្ថាបនា ទទួលបានឥណទានចំនួន **៤.០១៧.៦៨០,២៦ ដុល្លារអាមេរិក**។ បន្ថែមពីនេះ ក្នុងឆ្នាំ២០២៤ នេះ ស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរបានធ្វើការអនុម័ត និងបញ្ចេញឥណទាន ដល់អតិថិជនចំនួន **២៤០ រូប** ដែលសរុបជាទឹកប្រាក់ ចំនួន **៥.២៦៩.៧៥៧,៤៩ ដុល្លារអាមេរិក** ក្នុងនោះធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានបញ្ចេញឥណទានដែលសរុបជាទឹកប្រាក់ ចំនួន **២.១៤៣.០០០ ដុល្លារអាមេរិក** ដល់អតិថិជនចំនួន **៦២ រូប** និងធនាគារស្ថាបនា បានបញ្ចេញឥណទានដែលសរុបជាទឹកប្រាក់ចំនួន **៣.១២៦.៧៥៧,៤៩ ដុល្លារអាមេរិក** ដល់អតិថិជនចំនួន **១៧៨ រូប**។ ក្នុងចំណោមអតិថិជនទាំង **២៤០ រូប** ក្នុងនោះរួមមាន កសិធុរកិច្ចចំនួន **៧**, អាជីវកម្មគាំទ្រចំនួន **៧**, សហគមន៍កសិកម្មចំនួន **៨**, សមាជិកសហគមន៍កសិកម្ម ចំនួន **១៩៧** និង

កសិករចិញ្ចឹមមាន់ស្រែចំនួន **២១** ដើម្បីប្រើប្រាស់ក្នុងខ្សែច្រវាក់តម្លៃផលិតផល កសិកម្មគោលដៅចំនួន ៥៖ ស្វាយចន្ទី មាន់ស្រែ ដំឡូងមី បន្លែ និងស្វាយ។
















លើសពីនេះ **ន.ម.ធ.** ដែលជាអង្គភាពអនុវត្តគម្រោង ACSEP សម្រាប់សមាសភាគទី១ ក៏បានរៀបចំវគ្គបណ្តុះបណ្តាល ជាច្រើនដល់មន្ត្រីបង្គោល និងស្ថាប័នហិរញ្ញវត្ថុដៃគូរ អំពីនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីឥណទាន និងមូលនិធិធានាឥណទាន (SOPs) និងផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារសមាសភាគទី១ និងបុគ្គលិកស្ថាប័នហិរញ្ញវត្ថុដៃគូរលើគោលការណ៍ប្រតិបត្តិរួម (GoG) ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ និងកសាងសមត្ថភាពសម្រាប់អតិថិជនសក្តានុពលជាបន្តបន្ទាប់អំពីនីតិវិធី លក្ខខ័ណ្ឌ ការរៀបចំខ្លួន និងឱកាសក្នុងការទទួលបានឥណទានពីគម្រោង ACSEP នៅក្នុងខេត្តគោលដៅនៃគម្រោង។ ក្នុងឆ្នាំ២០២៤ នេះ **ន.ម.ធ.**

បានរៀបចំ និងចូលរួមវគ្គបណ្តុះបណ្តាលនៃអនុវត្តគម្រោង ACSEP **ចំនួន ១៨ លើក** ដែលមានអ្នកចូលរួមសរុបប្រមាណ **៣.៥៧០ រូប** នៅតាមខេត្តគោលដៅចំនួន ៦ និងរាជធានី ផងដែរ។

ក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ការផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចីរបស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម, ក្នុងឆ្នាំ ២០២៤ នេះ ក្នុងក្របខ័ណ្ឌអនុវត្តគម្រោង ACSEP សមាសភាគទី១ បានរៀបចំសិក្ខាសាលាស្តីពី **"ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"** ដល់ខេត្តគោលទាំង ៦ ដូចខាងក្រោម៖

- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" កាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ នៅខេត្តសៀមរាប
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" កាលពីថ្ងៃទី៧-៩ ខែឧសភា ឆ្នាំ២០២៤ នៅខេត្តឧត្តរមានជ័យ
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នៅខេត្តព្រះវិហារ
- វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាន (កម្ចី) ដល់សមាគមស្វាយចន្ទីកម្ពុជា និងកសិករចិញ្ចឹមមាន់ស្រុក" កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ នៅខេត្តកំពង់ធំ
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" កាលពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ ក្នុងខេត្តកំពង់ចាម
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" កាលពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៤ ក្នុងខេត្តត្បូងឃ្មុំ
- វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាននៃគម្រោង ACSEP កម្រិតសហគមន៍" នៅខេត្តកំពង់ធំ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤។

















បន្ថែមពីនេះ ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុទាំងពីរលើការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម ដែលជាលក្ខខណ្ឌតម្រូវរបស់ ADB ក្នុងឯកសារស្នើសុំឥណទាន (កម្ចី) របស់គម្រោង ក៏មានការរៀបចំនូវកម្មវិធីកសាងសមត្ថភាពតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួន ដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាលស្តីពី "**របៀបរៀបចំ និងសរសេររបាយការណ៍ហិរញ្ញវត្ថុ**" ត្រូវបានរៀបចំ កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤
- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញអំពី "**ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម - ESMS Info.Sheet.**" ត្រូវបានរៀបចំ កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ នៅខេត្តសៀមរាប
- វគ្គបណ្តុះបណ្តាលស្តីពី "**ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន**" ត្រូវបានរៀបចំ កាលពីថ្ងៃទី ២២-២៤ ខែតុលា ឆ្នាំ២០២៤ នៅខេត្តឧត្តរមានជ័យ ព្រះវិហារ និងខេត្តសៀមរាប
- វគ្គបណ្តុះបណ្តាលស្តីពី "**ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្មសមាសភាគទី១**" ត្រូវបានរៀបចំ កាលពីថ្ងៃ២០-២២ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តត្បូងឃ្មុំ កំពង់ចាម និងកំពង់ធំ
- វគ្គបណ្តុះបណ្តាលស្តីពី "**ការពង្រឹងសមត្ថភាពមន្ត្រីលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគោលការណ៍ប្រតិបត្តិការឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១**" ត្រូវបានរៀបចំ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ នៅខេត្តសៀមរាប។



**រូបភាព៖** វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុទាំងពីរ។

ជាមួយគ្នានេះ ក្នុងគោលបំណងដើម្បីពិភាក្សាលើបញ្ហាប្រឈម កាលានុវត្តភាព និងស្វែងរកដំណោះស្រាយដែលបានអនុវត្តកន្លងមក និងសំណូមពរនានារបស់អង្គភាពពាក់ព័ន្ធ ជាពិសេសស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ ក្នុងដំណើរការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទាន ដើម្បីឈានទៅរកដំណោះស្រាយសមស្របរួមគ្នាមួយសម្រាប់ការរៀបចំយុទ្ធសាស្ត្រអនុវត្តបន្តបន្ទាប់ **ន.ប.ធ.** ក៏បានរៀបចំនូវកិច្ចប្រជុំ និង/ឬសិក្ខាសាលានានាផងដែរ រួមមាន៖ ១- សិក្ខាសាលាស្តីពី "**ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤**" កាលពីថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ២០២៤ និង ២- សិក្ខាសាលាស្តីពី "**ការបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២៤ របស់អង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១**" កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤។








**រូបភាព៖** សិក្ខាសាលាបូកសរុបលទ្ធផលការងារអនុវត្តគម្រោង ACSEP សមាសភាគទី១។

## ៤.៦.២. កម្មវិធីសង្គម

ទន្ទឹមនឹងការខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួន **ន.ប.ធ.** ក៏បានចូលរួមយ៉ាងសកម្មក្នុងការងារសង្គមកិច្ច សកម្មភាពសហគមន៍ ក្នុងន័យជួយសម្រួលទុក្ខលំបាករបស់កុមារកំព្រា ដើម្បីចូលរួមក្នុងការងារលើកស្ទួយកម្ពស់ជីវភាព និងឈានទៅរកការអភិវឌ្ឍសង្គមមួយដែលមាននិរន្តរភាព សេដ្ឋកិច្ច និងបរិស្ថាន។ កន្លងមកនេះ **ន.ប.ធ.** បានរៀបចំកម្មវិធីសប្បុរសធម៌ ចំនួន ៤ លើក រួមមាន៖







**រូបភាព៖** កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។








**រូបភាព៖** កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤។







**រូបភាព៖** កម្មវិធីសង្គម នៅមណ្ឌលកុមារកំព្រាខេត្តសៀមរាប នៅខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។







**រូបភាព៖** កម្មវិធីសប្បុរសធម៌នៅអង្គការវិទ្យាស្ថានអភិវឌ្ឍន៍វប្បធម៌ខ្មែរ នៅខេត្តកំពត ថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០២៤។

បន្ថែមពីនេះ **ន.ប.ធ.** បាននាំយកអំណោយជាសម្ភារៈប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ជាពិសេស សេចក្តីស្រលាញ់ សេចក្តីសង្ឃឹម ការយកចិត្តទុកដាក់ ការចែករំលែកនូវបទពិសោធន៍ជីវិតនិងការងារ ក៏ដូចជាផ្តល់កម្លាំងចិត្តដល់កុមារ ដើម្បីក្លាយជាទំពាំងស្នងដ៏រឹងមាំរបស់សង្គមនៅថ្ងៃអនាគត។ ជាការពិតធនធានមនុស្សក៏ជាបច្ច័យដ៏ចាំបាច់បំផុតក្នុងការសម្រេចបានតាមទិសដៅនៃការអភិវឌ្ឍជាតិដើម្បីចូលរួមជាផ្នែកមួយក្នុងការបង្កើនធនធានមនុស្ស **ន.ប.ធ.** បានផ្តួចផ្តើមគំនិតកសាងអគារសាលាបឋមសិក្សាថ្មី ១ ខ្នង មាន ៤ បន្ទប់ បំពាក់ដោយបរិក្ខារ ព្រមទាំងបន្ទប់ទឹកអនាម័យ ដែលមានទីតាំងស្ថិតនៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ ដោយមានការចូលរួមឧបត្ថម្ភគាំទ្រពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងក្រុមបរធនបាល ដែលការសាងសង់នេះបានចាប់ផ្តើមនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៤ និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅក្នុងថ្ងៃទី១២ ខែមករា ឆ្នាំ២០២៥។ **ន.ប.ធ.** មានក្តីសង្ឃឹមយ៉ាងមុតមាំថាអគារសាលា១ខ្នងនេះ នឹងក្លាយជាថ្នាលប្រយោជន៍ក្នុងការបណ្តុះបណ្តាលកុមារឱ្យក្លាយទៅជាបញ្ញវន្តដ៏ល្អប្រពៃក្នុងសង្គមជាតិ។








**រូបភាព៖** កម្មវិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសាលាបឋមសិក្សា នៅថ្ងៃ២៣ មិថុនា ឆ្នាំ២០២៤។

## ផ្នែកទី៥
## ឧបសម្ព័ន្ធ
### ឧបសម្ព័ន្ធទី១៖ ក្រុមបទដ្ឋានគតិយុត្តក្នុងវិស័យបរធនបាលកិច្ច

| ល.រ. | បទដ្ឋានគតិយុត្ត | កាលបរិច្ឆេទ |
|---|---|---|
| | **ច្បាប់** | |
| ១ | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១៦ មករា ២០២១ |
| ២ | ច្បាប់ស្តីពីបរធនបាលកិច្ច | ២ មករា ២០១៩ |
| | **អនុក្រឹត្យ** | |
| ១ | អនុក្រឹត្យស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច | ២៧ មករា ២០២៣ |
| ២ | អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១៤ កក្កដា ២០២១ |
| ៣ | អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច | ២ សីហា ២០១៩ |
| ៤ | អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ | ២៦ សីហា ២០១៣ |
| | **ប្រកាស** | |
| ១ | ប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនសេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច | ៣ មករា ២០២៤ |
| ២ | ប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច | ៣ មករា ២០២៤ |
| ៣ | ប្រកាសស្តីពី កាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាលកិច្ច | ២០ ធ្នូ ២០២៣ |
| ៤ | ប្រកាសស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចបរធនបាលកិច្ច | ១៤ មិថុនា ២០២៣ |
| ៥ | ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ | ១៦ សីហា ២០២៣ |
| ៦ | ប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច | ៣ វិច្ឆិកា ២០២២ |
| ៧ | ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច | ៣ វិច្ឆិកា ២០២២ |
| ៨ | ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច | ១៨ កុម្ភៈ ២០២២ |
| ៩ | ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធន-បាលកិច្ច | ២៦ មករា ២០២២ |
| ១០ | ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១ តុលា ២០២១ |
| ១១ | ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោម | ១ តុលា ២០២១ |

| ល.រ. | បទដ្ឋានគតិយុត្ត | កាលបរិច្ឆេទ |
|---|---|---|
| | ឱវាទរបស់និយ័តករបរធនបាលកិច្ច | |
| ១២ | ប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីនៃនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ៨ កញ្ញា ២០២១ |
| ១៣ | ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច | ៣០ កញ្ញា ២០១៩ |
| ១៤ | ប្រកាសស្តីពីការកែសម្រួលប្រការ១២ នៃប្រកាសលេខ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធន-បាលកិច្ចហិរញ្ញវត្ថុ | ២៧ ធ្នូ ២០១៦ |
| ១៥ | ប្រកាសស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ | ២៦ កញ្ញា ២០១៤ |
| | **សេចក្តីសម្រេច សេចក្តីណែនាំ និងគោលការណ៍ណែនាំ** | |
| ១ | គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការដាក់ឱ្យចូលនិវត្តន៍របស់មន្ត្រីរាជការនៃនិយ័តករបរធនបាលកិច្ច | ១២ ធ្នូ ២០២៤ |
| ២ | គោលការណ៍ណែនាំស្តីពីការពង្រឹងសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់និយ័តករបរធនបាលកិច្ច | ១៣ ធ្នូ ២០២៤ |
| ៣ | សេចក្តីណែនាំស្តីពីការស្នើសុំប្រើប្រាស់បន្ទប់ប្រជុំរបស់និយ័តករបរធនបាលកិច្ច | ១២ ធ្នូ ២០២៤ |
| ៤ | សេចក្តីណែនាំស្តីពីយន្តការ និងនីតិវិធីនៃការសុំច្បាប់ឈប់សម្រាកសម្រាប់មន្ត្រីនៃនិយ័តករបរធនបាលកិច្ច នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា | ១៦ ធ្នូ ២០២៤ |
| ៥ | សេចក្តីណែនាំស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីនៃនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១៣ ធ្នូ ២០២៤ |
| ៦ | សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីផ្ទៃក្នុងសម្រាប់អនុវត្តកិច្ចការគ្រប់គ្រងឯកសារចេញ-ចូល របស់និយ័តករបរធនបាលកិច្ច | ១៧ ធ្នូ ២០២៤ |
| ៧ | គោលការណ៍ណែនាំស្តីពី ទម្រង់របាយការណ៍របស់បរធនបាល | ៨ ឧសភា ២០២៤ |
| ៨ | គោលការណ៍ណែនាំស្តីពី បែបបទ និងយន្តការពិគ្រោះយោបល់ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច | ៣ កុម្ភៈ ២០២៣ |
| ៩ | សេចក្តីណែនាំស្តីពី ការគ្រប់គ្រងវត្តមានសម្រាប់មន្ត្រីនៃ **ន.ប.ធ.** | ២៨ មេសា ២០២៣ |
| ១០ | គោលការណ៍ណែនាំស្តីពី សណ្តាប់ធ្នាប់ អនាម័យ និងការប្រើប្រាស់ដោយថែរក្សានិងសំចៃនូវបរិក្ខា និងសម្ភារៈនៃ **ន.ប.ធ.** | ២២ មិថុនា ២០២៣ |
| ១១ | គោលការណ៍ណែនាំស្តីពី លក្ខខណ្ឌ និងនីតិវិធីក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច | ១១ កក្កដា ២០២៣ |
| ១២ | គោលការណ៍ណែនាំស្តីពី បែបបទ និងទម្រង់លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល របស់និយ័តករបរធនបាលកិច្ច | ១ កញ្ញា ២០២៣ |

| ល.រ. | បទដ្ឋានគតិយុត្ត | កាលបរិច្ឆេទ |
|---|---|---|
| ១៣ | គោលការណ៍ណែនាំស្តីពី បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច | ១២ ធ្នូ ២០២៣ |
| ១៤ | ផែនការអភិវឌ្ឍន៍ធនធានមនុស្ស នៃ **ន.ប.ធ.** | ២៩ ធ្នូ ២០២៣ |
| ១៥ | សេចក្តីណែនាំស្តីពី "ការរាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដោយបុគ្គលរាយការណ៍សម្រាប់វិស័យបរធនបាលកិច្ច" | ៦ មេសា ២០២២ |
| ១៦ | គោលការណ៍ណែនាំរួមស្តីពី "ការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ" | ៣០ មីនា ២០២២ |
| ១៧ | សេចក្តីណែនាំស្តីពី "ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច" | ២១ កញ្ញា ២០២២ |
| ១៨ | គោលការណ៍ណែនាំអំពីបែបបទ និងទម្រង់លិខិតរដ្ឋបាលរបស់និយ័តករបរធនបាលកិច្ច | ១៨ តុលា ២០២២ |
| ១៩ | គោលការណ៍លើកទឹកចិត្តមន្ត្រីនៃនិយ័តករបរធនបាលកិច្ច | ២៨ ធ្នូ ២០២២ |
| ២០ | សេចក្តីណែនាំលើការរៀបចំគម្រោងថវិការបស់ **ន.ប.ធ.** | ៦ តុលា ២០២២ |
| ២១ | គោលការណ៍ណែនាំស្តីពី នីតិវិធីផ្ទៃក្នុងសម្រាប់ការរៀបចំ និងការអនុវត្តថវិកាកម្មវិធីរបស់និយ័តករបរធនបាលកិច្ច | ៦ តុលា ២០២២ |
| ២២ | គោលការណ៍ណែនាំស្តីពី ការបើកប្រាក់បេសកកម្មក្នុងប្រទេស និងក្រៅប្រទេសតាមប្រព័ន្ធធនាគារសម្រាប់មន្ត្រីនៃនិយ័តករបរធនបាលកិច្ច | ៦ តុលា ២០២២ |
| ២៣ | សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មការវាយតម្លៃសមិទ្ធកម្មមន្ត្រីនៃ **ន.ប.ធ.** | ២៤ មករា ២០២២ |

## ឧបសម្ព័ន្ធទី២៖ ព្រឹត្តិការណ៍សំខាន់ៗក្នុងវិស័យបរធនបាលកិច្ច

| ល.រ. | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ |
|---|---|---|
| ១ | សិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" | ៩ មករា ២០២៤ |
| ២ | សិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច" | ១៦ មករា ២០២៤ |
| ៣ | វគ្គបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ | ២៩-១ មករា-កុម្ភៈ ២០២៤ |
| ៤ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ **ន.ប.ធ.** ជាផ្លូវការ | ១៦ កុម្ភៈ ២០២៤ |
| ៥ | កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត | ១៩ កុម្ភៈ ២០២៤ |
| ៦ | សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា | ២៣ កុម្ភៈ ២០២៤ |
| ៧ | សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា | ២៦ កុម្ភៈ ២០២៤ |
| ៨ | កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា | ១ មីនា ២០២៤ |
| ៩ | កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា | ១ មីនា ២០២៤ |
| ១០ | កម្មវិធី "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល" | ៣ មីនា ២០២៤ |
| ១១ | សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា | ១៥ មីនា ២០២៤ |
| ១២ | សិក្ខាសាលាស្តីពី ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច | ២៩ មីនា ២០២៤ |
| ១៣ | វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី "ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence ( AI )" | ០៥ មេសា ២០២៤ |
| ១៤ | កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ | ១១ មេសា ២០២៤ |
| ១៥ | កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** | ១៩ មេសា ២០២៤ |
| ១៦ | កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក | ៣០ មេសា ២០២៤ |
| ១៧ | សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" | ២ ឧសភា ២០២៤ |

| ល.រ. | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ |
|---|---|---|
| ១៨ | សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធន-បាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣)" | ៣ ឧសភា ២០២៤ |
| ១៩ | សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច" | ១១ ឧសភា ២០២៤ |
| ២០ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពីទម្រង់របាយការណ៍របស់បរធនបាល" | ២៤ ឧសភា ២០២៤ |
| ២១ | សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" | ២៧ ឧសភា ២០២៤ |
| ២២ | សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" | ៥ មិថុនា ២០២៤ |
| ២៣ | សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" | ១០ មិថុនា ២០២៤ |
| ២៤ | កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" | ២០ មិថុនា ២០២៤ |
| ២៥ | សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" | ២៤ មិថុនា ២០២៤ |
| ២៦ | កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" | ២៥ មិថុនា ២០២៤ |
| ២៧ | សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច" | ២៩ មិថុនា ២០២៤ |
| ២៨ | កម្មវិធីប្រកាសបើក "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យ បរធនបាលកិច្ច លើកទី៥" | ១ កក្កដា ២០២៤ |
| ២៩ | កម្មវិធីបាឋកថា ក្រោមប្រធានបទស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា" | ៣ កក្កដា ២០២៤ |
| ៣០ | កិច្ចពិភាក្សា៖ សក្តានុពលនៃយន្តការបរធនបាលកិច្ច និងនិន្នាការថ្មីៗនៃសេដ្ឋកិច្ច និងបច្ចេកវិទ្យា | ៣ កក្កដា ២០២៤ |
| ៣១ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់ការវិនិយោគ" | ៧ កក្កដា ២០២៤ |
| ៣២ | កិច្ចការការងារសង្គម នៅមណ្ឌលកុមារកំព្រាខេត្តសៀមរាប | ១៥ កក្កដា ២០២៤ |
| ៣៣ | កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" | ១៥ កក្កដា ២០២៤ |
| ៣៤ | កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** | ១៥ កក្កដា ២០២៤ |

| ល.រ. | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ |
|---|---|---|
| ៣៥ | ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ម.ធ.** និងក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក. | ១៥ សីហា ២០២៤ |
| ៣៦ | សិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" | ១៦ សីហា ២០២៤ |
| ៣៧ | សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច" | ២០ សីហា ២០២៤ |
| ៣៨ | ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ម.ធ.** និងក្រុមហ៊ុន អាយជី ថិក គ្រុប | ២៦ សីហា ២០២៤ |
| ៣៩ | សិក្ខាសាលាពិគ្រោះយោបល់លើកទី៣ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" | ២៨ សីហា ២០២៤ |
| ៤០ | ពិធីចុះអនុស្សរណៈរវាង **ន.ម.ធ.** ក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក | ២ កញ្ញា ២០២៤ |
| ៤១ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស" | ១៧ កញ្ញា ២០២៤ |
| ៤២ | កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" | ១៨ កញ្ញា ២០២៤ |
| ៤៣ | កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" | ២៣ កញ្ញា ២០២៤ |
| ៤៤ | កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ម.ធ.** | ៨ តុលា ២០២៤ |
| ៤៥ | កិច្ចប្រជុំស្តីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបរធនបាលកិច្ច" | ៨ តុលា ២០២៤ |
| ៤៦ | វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា" | ១៦ តុលា ២០២៤ |
| ៤៧ | វេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត" | ៣០ តុលា ២០២៤ |
| ៤៨ | សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" | ៧ វិច្ឆិកា ២០២៤ |
| ៤៩ | កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" | ២៥ វិច្ឆិកា ២០២៤ |

| ល.រ. | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ |
|---|---|---|
| ៥០ | សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" | ៤ ធ្នូ ២០២៤ |
| ៥១ | សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល" | ៦ ធ្នូ ២០២៤ |
| ៥២ | សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច" | ៩ ធ្នូ ២០២៤ |
| ៥៣ | សិក្ខាសាលាស្តីពី "បច្ចេកទេសក្នុងការសរសេរអត្ថបទគតិយុត្ត" | ២៤ ធ្នូ ២០២៤ |
| ៥៤ | កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារបន្ត | ២៥ ធ្នូ ២០២៤ |

## ឧបសម្ព័ន្ធទី៣៖ ប្រតិបត្តិករក្នុងវិស័យបរធនបាលកិច្ច

| និមិត្តសញ្ញា | ក្រុមហ៊ុន/ធនាគារ | កាលបរិច្ឆេទ |
|---|---|---|
| | **ក្រុមហ៊ុនបរធនបាល** | |
| | ក្រុមហ៊ុន កាណា ត្រាស ឯ.ក<br>CANA TRUST CO., LTD. | ១៥ ធ្នូ ២០២២ |
| | ក្រុមហ៊ុន ហ្វីលីព ត្រាសធី(ខេមបូឌា) ឯ.ក<br>Phillip Trustee Co., Ltd. | ១៥ ធ្នូ ២០២២ |
| | ក្រុមហ៊ុន អេសជី ថបត្រាស ឯ.ក<br>SG TOP TRUST Co., Ltd. | ២៤ មករា ២០២៣ |
| | ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក<br>STRONGHOLD TRUSTEE Co., Ltd. | ៣ កុម្ភៈ ២០២៣ |
| | ក្រុមហ៊ុន ប៊ី.អាយ.ស៊ីត្រាស ឯ.ក<br>B.I.C Trustee **Co., Ltd.** | ២៩ មីនា ២០២៣ |
| | ក្រុមហ៊ុនដឹ ហ្វឹសឆាយណាអ៊ិនវេសមេន អេនត្រាសឯ.ក<br>THE FIRST CHINA INVESTMENT & TRUST Co., Ltd. | ១៧ មិថុនា ២០២៣ |
| | ធនាគារ ស៊ីអាយអិមប៊ីភីអិលស៊ី<br>CIMB Bank Plc. | ២ សីហា ២០២៣ |
| | ក្រុមហ៊ុន ហ្គ្រេន កាថេ អ៊ិនវេសម៉ិន ត្រាស(ខេមបូឌា) ម.ក<br>GRAND CATHAY INVESTMENT ( CAMBODIA ) PLC. | ២៣ វិច្ឆិកា ២០២៣ |
| | ក្រុមហ៊ុន ព្រីនស៍ ត្រាស់ ឯ.ក<br>Prince Trust Co., Ltd. | ៨ ធ្នូ ២០២៣ |
| | ក្រុមហ៊ុន អេស អ៊ិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឹមេន ឯ.ក<br>Accounting & Consulting Co., Ltd. | ១១ មេសា ២០២៤ |
| | ក្រុមហ៊ុន ស៊ីស៊ីយូ ត្រាស់ ឯ.ក<br>CCU Trust Co., Ltd. | ៧ ឧសភា ២០២៤ |
| | ក្រុមហ៊ុន អិកស៍ ត្រាស់ ឯ.ក<br>X TRUST Co., LTD. | ១៩ កក្កដា ២០២៤ |
| | ក្រុមហ៊ុន អវតា គ្លូបិលវេនឈ័រ ឯ.ក<br>AVATAR GLOBAL VENTURES Co., Ltd. | ៣០ សីហា ២០២៤ |

| និមិត្តសញ្ញា | ក្រុមហ៊ុន/ធនាគារ | កាលបរិច្ឆេទ |
|---|---|---|
| | ប្រតិបត្តិករបេឡាធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក | |
| | ធនាគារ អេស៊ីលីដាភីអិលស៊ី<br>ACLEDA BANK Plc. | ១២ សីហា ២០២២ |
| | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA)<br>ABA BANK Plc. | ១៥ កុម្ភៈ ២០២៣ |
| | ធនាគារ ហ្វីលីព ភីអិលស៊ី<br>PhillipBank Plc. | ១ មីនា ២០២៣ |
| | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក<br>J Trust Royal Plc. | ២៨ មីនា ២០២៣ |
| | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិកឌីវេឡុបមេន ម.ក<br>ASIAN DEVELOPMENT BANK Plc. | ១១ មេសា ២០២៣ |
| | ធនាគារ មេយប៊ែង(ខេមបូឌា) ភីអិលស៊ី<br>MayBank (Cambodia) Plc. | ១៤ មិថុនា ២០២៣ |
| | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី<br>Bred Bank (Cambodia) Plc. | ២៧ មិថុនា ២០២៣ |
| | ធនាគារ វីង (ខេមបូឌា) ម.ក<br>Wing Bank (Cambodia) Plc. | ៥ កក្កដា ២០២៣ |
| | ធនាគារ ស្ថាបនា ភីអិលស៊ី<br>Sathapan Bank Plc. | ១៧ កក្កដា ២០២៣ |
| | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី<br>CIMB BANK Plc. | ២ សីហា ២០២៣ |
| | ធនាគារ ប៊ី.អាយ.ស៊ី(ខេមបូឌា) ប៊ែង ម.ក<br>B.I.C BANK (CAMBODIA) Plc. | ៨ សីហា ២០២៣ |
| | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក<br>PPC BANK Plc. | ២ តុលា ២០២៣ |
| | ធនាគារ កាណាឌីយ៉ា ក.អ<br>CANADIA BANK Plc. | ៤ តុលា ២០២៣ |
| | ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក<br>SBI LY HOUR BANK Plc. | ១៥ មករា ២០២៤ |

| និមិត្តសញ្ញា | ក្រុមហ៊ុន/ធនាគារ | កាលបរិច្ឆេទ |
|---|---|---|
| CCU bank | ធនាគារ ស៊ីស៊ីយូ ខមមើសល បែង ម.ក<br>CCU Commercial Bank Plc. | ១៩ មករា ២០២៤ |
| Shinhan Bank | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក<br>Shinhan Bank (Cambodia) Plc. | ២៦ មករា ២០២៤ |
| | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ<br>CP BANK Plc. | ២៨ ឧសភា ២០២៤ |
| UCB ធនាគារ សហពាណិជ្ជ ក.អ UNION COMMERCIAL BANK PLC. 聯合商業銀行 | ធនាគារ សហពាណិជ្ជ ក.អ<br>UNION COMMERCIAL BAN PLC. | ២៣ កក្កដា ២០២៤ |
| ធនាគារពាណិជ្ជ អាល់ហ្វា ម.ក ALPHA COMMERCIAL BANK PLC. 澳法商业银行 | ធនាគារ ពាណិជ្ជ អាល់ហ្វា ម.ក<br>ALPHA COMMERCIAL BANK PLC. | ២ សីហា ២០២៤ |
| ធនាគារ វឌ្ឍនៈ | ធនាគារ វឌ្ឍនៈ<br>Vatthanak Bank Plc. | ១៣ សីហា ២០២៤ |
| RHB | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក<br>RHB (CAMBODIA) PLC. | ២០ សីហា ២០២៤ |
| ធនាគារ អូរៀនថល Oriental Bank 东方银行 | ធនាគារ អូរៀនថល ម.ក<br>Oriental Bank Plc. | ១៦ តុលា ២០២៤ |
| ធនាគារ កាថេ យូណៃធីត Cathay United Bank | សាជីវកម្មធនាគារ កាថេយូណៃធីត (កម្ពុជា) ចំកាត់<br>Cathay United Bank Plc. | ២ ធ្នូ ២០២៤ |
| Hong Leong Bank | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី<br>HongLeon Bank (Cambodia) Plc. | ១២ ធ្នូ ២០២៤ |
| **ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច** | | |
| QUANTUM SPECTRUM IN THE KNOW | ក្រុមហ៊ុន ខ្វនថឹម & ស្ពេកត្រឹម ឯ.ក<br>QUANTUM SPECTRUM CO., LTD. | ២៩ កុម្ភៈ ២០២៤ |
| pwc | ក្រុមហ៊ុន ប្រាយវ៉តធ័រហោរ ខូភើស៍ (ខេមបូឌា) | ២៩ កុម្ភៈ ២០២៤ |
| EY Building a better working world | ក្រុមហ៊ុន អឺនស្ទ៍ អែនយ៉ាំង(ខេមបូឌា)<br>Ernst & Young (Cambodia) Co., Ltd. | ៤ មីនា ២០២៤ |
| SM Global Accounting & Consulting Co., Ltd. 에스엠 會計法人 | ក្រុមហ៊ុន អេស អិម គ្លូបិល អឺខោនធីង & ខនសាល់ធីង<br>Accounting & Consulting Co., Ltd. | ៤ មីនា ២០២៤ |

| និមិត្តសញ្ញា | ក្រុមហ៊ុន/ធនាគារ | កាលបរិច្ឆេទ |
|---|---|---|
| | ក្រុមហ៊ុន ថៃ អេន ឡ្យ មេនេចម៉ិន ខនសាល់ធេន ឯ.ក<br>Management Consultant Co., Ltd. | ៤ មីនា ២០២៤ |
| | ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក<br>Bakertilly (Cambodia) Co., Ltd. | ១៥ មីនា ២០២៤ |
| | ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា<br>KPMC (Cambodia) Co., Ltd. | ១៩ មីនា ២០២៤ |
| | ក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី<br>Deloitte (Cambodia) Co., Ltd. | ២០ មីនា ២០២៤ |
| | ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត<br>GrantThornton (Cambodia) Limited Co., Ltd. | ២១ មីនា ២០២៤ |
| | ក្រុមហ៊ុន ប្លូ ឆាធើរ អឹខោនថិន អេន អឌីតធ័រ ឯ.ក<br>BLUE Chatered Accountants and Auditors Co., Ltd. | ២៩ មីនា ២០២៤ |
| | ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក<br>Crowe (KH) Co., Ltd. | ២៩ មីនា ២០២៤ |
| | ក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត<br>FII & Associate Co., Ltd. | ២៩ មេសា ២០២៤ |
| | ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត<br>BDO (Cambodia) Limited Co., Ltd. | ១០ ឧសភា ២០២៤ |
| | ក្រុមហ៊ុន រីចឆ៍ & ផាតនើរ<br>REACHS & PARTNER Co., Ltd. | ១០ ឧសភា ២០២៤ |
| | ក្រុមហ៊ុន ខេម អឹខោនធីង & ថាក សឺវីស ឯ.ក<br>CAM ACCONTING & TAX SERVINCE Co., Ltd. | ២៧ សីហា ២០២៤ |
| **ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច** | | |
| | ក្រុមហ៊ុន មេហ្គា អាសិត មេនេចមិន<br>Mega Asset Management Co., Ltd. | ២២ កុម្ភៈ ២០២៣ |
| | ក្រុមហ៊ុន ខូហ្ស៊ីហូម ឯ.ក<br>COZY HOME CO., LTD. | ២២ កុម្ភៈ ២០២៣ |
| | ក្រុមហ៊ុន ស៊ី ភី អែល ខេមបូឌា ប្រភើធី លីមីតធីត<br>CPL CAMBODIA PROPERTY LIMITED Co., Ltd. | ២២ កុម្ភៈ ២០២៣ |

| និមិត្តសញ្ញា | ក្រុមហ៊ុន/ធនាគារ | កាលបរិច្ឆេទ |
|---|---|---|
| | ក្រុមហ៊ុន ខ្មែរ រៀល អ៊ីស្តេត ឯ.ក<br>KHMER REAL ESTATE CO., LTD. | ២៣ មីនា ២០២៣ |
| | ក្រុមហ៊ុន ខ្មែរ ហ្វោនដេសិន អឹព្រេហ្សល ខូអិលធីឌី<br>KHMER FOUNDATION APPRAISAL CO., LTD. | ១១ ឧសភា ២០២៣ |
| | ក្រុមហ៊ុន អេស អិម គ្លូបិល អឹព្រេហ្សល<br>Accounting & Consulting Co., Ltd. | ២៩ ឧសភា ២០២៣ |
| | ក្រុមហ៊ុន អ៊ិនឌីភេនដិនថ៍ ប្រផឹធី សឺវីស ខូល អិលធីឌី<br>INDEPENDENT PROPERTY SERVICES CO., LTD. | ៣០ ឧសភា ២០២៣ |
| | ក្រុមហ៊ុន ឃី រៀល អ៊ីស្តេត<br>KEY REAL ESTATE CO., LTD. | ១៦ មិថុនា ២០២៣ |
| | ខេត អឹព្រេហ្សល ឯ.ក<br>KAT APPRAISAL CO., LTD. | ៥ កក្កដា ២០២៣ |
| | ណាយ ហ្វ្រេង (ខេមបូឌា)<br>Knight Frank Co., Ltd. | ១១ កក្កដា ២០២៣ |
| | ក្រុមហ៊ុនអ៊ីនវ៉ា រៀលអ៊ីស្តេតអ៊ិនវេសម៉ិន អេនវ៉ាលូអេសិន ឯ.ក<br>INVA REAL ESTATE INVESTMENT & VALUATION CO., LTD. | ២៤ កក្កដា ២០២៣ |
| | ក្រុមហ៊ុន អេស៊ា រៀល អ៊ីស្តេត (ខេមបូឌា) ខូអិលធីឌី<br>ASIA REAL ESTATE CAMBODIA (CAMBODIA) CO., LTD. | ២៣ តុលា ២០២៣ |
| | ក្រុមហ៊ុន ឌីហ្គ្រេន រៀលធី ឯ.ក<br>ABRE Cambodia Co., Ltd. | ២១ វិច្ឆិកា ២០២៣ |
| | ក្រុមហ៊ុន អ៊ែតវ៉ានថិច ប្រផឹធី សឺវីស ឯ.ក<br>CBRE Cambodia | ២៩ កុម្ភៈ ២០២៤ |
| | ក្រុមហ៊ុន អាយ រៀល អ៊ីស្តេត<br>EYES REAL ESTATE CO., LTD. | ១៩ កក្កដា ២០២៤ |
| | ក្រុមហ៊ុន ឡាក់ឃី រៀលធី<br>LUCKY REAL ESTATE CO., LTD. | ១១ សីហា ២០២៤ |
| | ក្រុមហ៊ុន ផារ៉ាដាយ ប្រផឹធី វ៉ាលូអេសិន អេនធើប្រាយ ឯ.ក<br>PARADISE PROPERTY VALUATION ENTERPRISE CO., LTD. | ១៨ ធ្នូ ២០២៤ |

# ក្រុមការងាររៀបចំរបាយការណ៍សមិទ្ធផល ឆ្នាំ២០២៤

**ពិនិត្យ និងកែសម្រួលដោយ៖**

| | |
|---|---|
| ឯកឧត្តម **សុខ ដារ៉ា** | អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច |
| ឯកឧត្តម **នង ពិសិដ្ឋ** | អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច |
| ឯកឧត្តម **ឈី សាភល** | អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច |

**ក្រុមការងារស្នូល៖**

| | |
|---|---|
| លោក ប៉ូ សំអាង | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ |
| លោក ណាង សេរីវុធ | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ |
| លោក បៀន យាងជូ | ប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ |
| កញ្ញា កេត ស្រីនិច | អនុប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ |
| លោក បាន ចិន្តា | មន្ត្រី |
| កញ្ញា សម័យ ច័ន្ទម៉ីលី | មន្ត្រី |

**សហការផ្តល់ធាតុចូល និងមតិយោបល់៖**

នាយកដ្ឋានកិច្ចការទូទៅ

នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច

# និយ័តករបរធនបាលកិច្ច

វិស័យបរធនបាលកិច្ចជាវិស័យដ៏សំខាន់មួយក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ

@Trustregulator

អាស័យដ្ឋាន៖ អគារ ១៦៨ F (ជាន់ទី៨) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Address: Building 168F, (8th Floor), Street 598, Sangkat Chrang Chamres 1, Phnom Penh
ទំនាក់ទំនង/CONTACT៖ (855) 23 237 888